ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី ១៧ លេខ ២១ ត្រីមាសទី ០១ ឆ្នាំ ២០១៧

# រាជកិច្ច

ផ្សាយចេញពី

ទីស្តីការគណៈរដ្ឋមន្ត្រី

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច សារាចរ ប្រកាស

ក

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


២៧-០២-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/០២១៧/២៤៣ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ដល់នាយទាហាន ថ្នាក់វរសេនីយ៍ នៃកងយោធពលខេមរភូមិន្ទ ជូនយោធិនដែលបានចូលបម្រើកងទ័ព ពីខែ ធ្នូ ឆ្នាំ ១៩៧៩ ចុះ ចំនួន ៤៣៨ រូប ២០០៦

២៧-០២-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/០២១៧/២៤៤ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ជាកិច្ចបច្ឆាមរណៈ ដល់សពនាយទាហាន ថ្នាក់ឧត្តមសេនីយ៍ និងថ្នាក់វរសេនីយ៍ នៃកងយោធពលខេមរភូមិន្ទ ចំនួន ០៣ រូប ២០១៩

២៨-០២-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/០២១៧/២៤៥ ស្តីពី ការដាក់វិន័យលោក **សាំង សើរ** ចៅក្រមសាលាដំបូងខេត្តកោះកុង ក្រោមរូបភាព ផ្លាស់ដោយបង្ខំចាត់ឱ្យទៅក្រសួងយុត្តិធម៌ អាចតម្រូវឱ្យទទួលការបណ្តុះបណ្តាលបន្ថែម និងការព្យួរពីការងារមិនឱ្យមានបៀវត្ស ក្នុងរយៈពេល ០៤ (ប្រាំបួន) ខែ ២០២០

២៨-០២-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/០២១៧/២៤៦ ស្តីពី ការតែងតាំង និងផ្ទេរមុខតំណែង ប្រធាន អនុប្រធាន ចៅក្រម សាលាដំបូងរាជធានី-ខេត្ត ចំនួន ៥៤ រូប ២០២១


## II~រាជរដ្ឋាភិបាល

### អនុក្រឹត្យ


០៧-០៣-២០១៧ -អនុក្រឹត្យលេខ ៣៤ អនក្រ.បក ស្តីពី ការប្រគល់មុខងារគ្រប់គ្រងមណ្ឌលថែទាំកុមាររបស់រដ្ឋទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ការប្រគល់មុខងារត្រួតពិនិត្យមណ្ឌលថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាលទៅឱ្យរដ្ឋបាលរាជធានី ក្រុង ស្រុក និងការប្រគល់មុខងារគ្រប់គ្រងសេវាថែទាំកុមាររងគ្រោះ និងងាយរងគ្រោះ នៅក្នុងសហគមន៍ទៅឱ្យរដ្ឋបាលរាជធានី រដ្ឋបាលក្រុង និងរដ្ឋបាលឃុំ ២០២៦

២៧-០២-២០១៧ -អនុក្រឹត្យលេខ ២២០ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ២០៤១

២៧-០២-២០១៧ -អនុក្រឹត្យលេខ ២២១ អនក្រ.តត ស្តីពី ការតែងតាំងក្រុមប្រឹក្សាភិបាលទូរគមនាគមន៍កម្ពុជា ២០៤២

២៧-០២-២០១៧ -អនុក្រឹត្យលេខ ២២២ អនក្រ.តត ស្តីពី ការជូនមេដាយសុវត្ថារា ២០៤៤
២៧-០២-២០១៧ -អនុក្រឹត្យលេខ ២២៣ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ២០៤៦
២៧-០២-២០១៧ -អនុក្រឹត្យលេខ ២២៤ អនក្រ.តត ស្តីពី ការតែងតាំងផ្លាស់ប្តូរមុខងារ នាយទាហាន ២០៤៩
២៧-០២-២០១៧ -អនុក្រឹត្យលេខ ២២៥ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ២០៥០
២៧-០២-២០១៧ -អនុក្រឹត្យលេខ ២២៦ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ២០៥១
២៧-០២-២០១៧ -អនុក្រឹត្យលេខ ២២៧ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ២០៥២
២៨-០២-២០១៧ -អនុក្រឹត្យលេខ ២២៨ អនក្រ.តត ស្តីពី ការផ្លាស់ប្តូរប្រភេទក្របខ័ណ្ឌមន្ត្រីរាជការ ២០៥៤
២៨-០២-២០១៧ -អនុក្រឹត្យលេខ ២២៩ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ២០៥៥
២៨-០២-២០១៧ -អនុក្រឹត្យលេខ ២៣០ អនក្រ.តត ស្តីពី ការសម្រួលភារកិច្ចមន្ត្រីនគរបាលជាតិ ២០៥៦
២៨-០២-២០១៧ -អនុក្រឹត្យលេខ ២៣១ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ២០៥៧
២៨-០២-២០១៧ -អនុក្រឹត្យលេខ ២៣២ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ២០៥៨
២៨-០២-២០១៧ -អនុក្រឹត្យលេខ ២៣៣ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ២០៥៩
២៨-០២-២០១៧ -អនុក្រឹត្យលេខ ២៣៤ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ២០៦០
២៨-០២-២០១៧ -អនុក្រឹត្យលេខ ២៣៥ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិកម្ពុជា ២០៦១
២៨-០២-២០១៧ -អនុក្រឹត្យលេខ ២៣៦ អនក្រ.តត ស្តីពី ការតែងតាំងទីប្រឹក្សាក្រសួងមហាផ្ទៃ ២០៦២
២៨-០២-២០១៧ -អនុក្រឹត្យលេខ ២៣៧ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិកម្ពុជា ២០៦៣
២៨-០២-២០១៧ -អនុក្រឹត្យលេខ ២៣៨ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិកម្ពុជា ២០៦៥
០១-០៣-២០១៧ -អនុក្រឹត្យលេខ ២៣៩ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ២០៦៧
០១-០៣-២០១៧ -អនុក្រឹត្យលេខ ២៤០ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ២០៦៩
០១-០៣-២០១៧ -អនុក្រឹត្យលេខ ២៤១ អនក្រ.តត ស្តីពី ការតែងតាំងទីប្រឹក្សាក្រសួងមហាផ្ទៃ ២០៧០
០១-០៣-២០១៧ -អនុក្រឹត្យលេខ ២៤២ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិមន្ត្រីរាជការ ២០៧១
០១-០៣-២០១៧ -អនុក្រឹត្យលេខ ២៤៣ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ២០៧៣
០១-០៣-២០១៧ -អនុក្រឹត្យលេខ ២៤៤ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ២០៧៥
០១-០៣-២០១៧ -អនុក្រឹត្យលេខ ២៤៥ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ២០៧៧
០១-០៣-២០១៧ -អនុក្រឹត្យលេខ ២៤៦ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ២០៧៩
០១-០៣-២០១៧ -អនុក្រឹត្យលេខ ២៤៧ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ២០៨០

# គ


០១-០៣-២០១៧ -អនុក្រឹត្យលេខ ២៤៨ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ២០៨១

០១-០៣-២០១៧ -អនុក្រឹត្យលេខ ២៤៩ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ២០៨២

០១-០៣-២០១៧ -អនុក្រឹត្យលេខ ២៥០ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ២០៨៤

០១-០៣-២០១៧ -អនុក្រឹត្យលេខ ២៥១ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ២០៨៦

០៣-០៣-២០១៧ -អនុក្រឹត្យលេខ ២៥២ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ២០៩៥


## III.ភាគខាងបណ្តាក្រសួង

## ទីស្តីការក្រសួងមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ


២០-០២-២០១៧ -ប្រកាសអន្តរក្រសួងលេខ ១៧៦ សហវ.ប្រក ស្តីពី ការបង្កើតវដ្តទេយ្យបុរេប្រទាន សម្រាប់ ឆ្នាំ ២០១៧ របស់នាយកដ្ឋានបុគ្គលិក ២០៩៨

២១-០២-២០១៧ -ប្រកាសអន្តរក្រសួងលេខ ១៨៣ សហវ.ប្រក ស្តីពី ការបង្កើតវដ្តទេយ្យបុរេប្រទាន សម្រាប់ ឆ្នាំ ២០១៧ របស់នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ ២១០២

# ព្រះរាជក្រឹត្យ

នស/រកត/០២១៧/៧៤៣

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាស ឲ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលតួនាទីភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំងរបស់ អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅ ចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តម្លើងឋានន្តរស័ក្តិ ដល់ នាយទាហាន ថ្នាក់វរសេនីយ៍ នៃកងយោធពលខេមរភូមិន្ទ ជូនយោធិនដែលបានចូលបម្រើកងទ័ពពីខែ ធ្នូ ឆ្នាំ១៩៧៩ចុះ ៖

**ក-ឋានន្តរស័ក្តិឧត្តមសេនីយ៍ត្រី :**

១-វរសេនីយ៍ឯក **គីម ម៉ុនវ៉ាល់** អត្តលេខ ០០០៦៤៣
២-វរសេនីយ៍ឯក **ជា ថេត** អត្តលេខ ០១៧៥១០
៣-វរសេនីយ៍ឯក **ម៉ិច សាខន** អត្តលេខ ០១៣៨៦៣
៤-វរសេនីយ៍ឯក **សុ ចណ្ណារ៉ា** អត្តលេខ ០០១១៩៧
៥-វរសេនីយ៍ឯក **គីម ចាន់ថន** អត្តលេខ ០០១៥៤៣
៦-វរសេនីយ៍ឯក **ហុក អូន** អត្តលេខ ០០១៥៤២
៧-វរសេនីយ៍ឯក **ឈន សេង** អត្តលេខ ០០២២០៦
៨-វរសេនីយ៍ឯក **ខាន់ សុវណ្ណរិទ្ធិ** អត្តលេខ ០០៣៤១៣
៩-វរសេនីយ៍ឯក **ផន ចន្ទ័រត្ន័** អត្តលេខ ០០៨៤៦៤
១០-វរសេនីយ៍ឯក **មៀង ឈាង** អត្តលេខ ០០៨៤៦៦
១១-វរសេនីយ៍ឯក **ឡោក ស៊ីណា** អត្តលេខ ០០៨៤៦៥
១២-វរសេនីយ៍ឯក **កឹង គីរ៉ា** អត្តលេខ ០០៣៣៤៦
១៣-វរសេនីយ៍ឯក **មង សារិន** អត្តលេខ ០១៤១៥០

| | | | |
|---|---|---|---|
| ១៤-វរសេនីយ៍ឯក | កែន | សារិទ្ធ | អត្តលេខ ០០១៥៣៧ |
| ១៥-វរសេនីយ៍ឯក | ម៉ន | ទូច | អត្តលេខ ០០៨៦២៤ |
| ១៦-វរសេនីយ៍ឯក | វ៉ាយ | សារឿន | អត្តលេខ ០០៨៦២៣ |
| ១៧-វរសេនីយ៍ឯក | ហ៊ុយ | រ៉ាវី | អត្តលេខ ០១៤១៣៩ |
| ១៨-វរសេនីយ៍ឯក | ម៉ម | រម្មណីយ | អត្តលេខ ០១៤១៥២ |
| ១៩-វរសេនីយ៍ឯក | សាត | សរម៉េង | អត្តលេខ ០០៨៤៦៧ |
| ២០-វរសេនីយ៍ឯក | ព្រាក | សារិន | អត្តលេខ ០១៤១៤៦ |
| ២១-វរសេនីយ៍ឯក | ហុង | ចំរើន | អត្តលេខ ០០២០៣២ |
| ២២-វរសេនីយ៍ឯក | ឈិន | សន | អត្តលេខ ០០២៣៦៩ |
| ២៣-វរសេនីយ៍ឯក | ឯក | ស៊ីវ | អត្តលេខ ០០១៤៣២ |
| ២៤-វរសេនីយ៍ឯក | ស៊ិន | ឌី | អត្តលេខ ០០១៤៤៣ |
| ២៥-វរសេនីយ៍ឯក | ខួន | សុផាត | អត្តលេខ ០១៣៨៤៨ |
| ២៦-វរសេនីយ៍ឯក | ជា | សុវណ្ណា | អត្តលេខ ០១៣៨៥៣ |
| ២៧-វរសេនីយ៍ឯក | ជិន | វណ្ណះ | អត្តលេខ ០០១៤៣៧ |
| ២៨-វរសេនីយ៍ឯក | ស្វាយ | សូដា | អត្តលេខ ០១៣៨៦១ |
| ២៩-វរសេនីយ៍ឯក | ណុប | គឹមថាន់ | អត្តលេខ ០០៨៣៨៥ |
| ៣០-វរសេនីយ៍ឯក | សរ | សំណាង | អត្តលេខ ០០២១៨៩ |
| ៣១-វរសេនីយ៍ឯក | និយម | បុល | អត្តលេខ ០០១៧៦២ |
| ៣២-វរសេនីយ៍ឯក | ជី | ចាន់ | អត្តលេខ ០១៤២៨៨ |
| ៣៣-វរសេនីយ៍ឯក | សយ | អិត | អត្តលេខ ០០៨៥៣៥ |
| ៣៤-វរសេនីយ៍ឯក | ខួន | សុផនណារិទ្ធិ | អត្តលេខ ០០១៥២៩ |
| ៣៥-វរសេនីយ៍ឯក | ឈុន | សាវុធ | អត្តលេខ ០០១៥២៨ |
| ៣៦-វរសេនីយ៍ឯក | ណាស៊ី | សាអ៊ុជ | អត្តលេខ ០០១៧៩៨ |
| ៣៧-វរសេនីយ៍ឯក | នាង | សំរេច | អត្តលេខ ០០៨៩៩៧ |
| ៣៨-វរសេនីយ៍ឯក | ឡុង | ម៉េង | អត្តលេខ ០០២១៨៧ |
| ៣៩-វរសេនីយ៍ឯក | កែវ | ណារិទ្ធ | អត្តលេខ ០០១៨១០ |
| ៤០-វរសេនីយ៍ឯក | ប៉ាន់ | វណ្ណា | អត្តលេខ ០០១៨០៦ |
| ៤១-វរសេនីយ៍ឯក | ឌិម | ខន្តី | អត្តលេខ ០០១៧៩៣ |
| ៤២-វរសេនីយ៍ឯក | ស៊ី | រ៉ា | អត្តលេខ ០០១៨០០ |
| ៤៣-វរសេនីយ៍ឯក | ពាន់ | ឌិន | អត្តលេខ ០០៨៥៣៩ |
| ៤៤-វរសេនីយ៍ឯក | កែវ | ធីរោ | អត្តលេខ ០០៨៥០១ |
| ៤៥-វរសេនីយ៍ឯក | យក់ | ស៊ីចាយ | អត្តលេខ ០២៥៤០៧ |
| ៤៦-វរសេនីយ៍ឯក | ហាឡុ | សិរីវុឌ្ឍ | អត្តលេខ ០១៩៨៦២ |
| ៤៧-វរសេនីយ៍ឯក | នង | សារ៉ាវី | អត្តលេខ ០០៨៥០២ |
| ៤៨-វរសេនីយ៍ឯក | សរ | មនោរិទ្ធី | អត្តលេខ ០៤៨៨៩២ |
| ៤៩-វរសេនីយ៍ឯក | ឈឹម | រត្ន័ | អត្តលេខ ០០០៥៦៩ |
| ៥០-វរសេនីយ៍ឯក | មាស | សាវ៉ាត | អត្តលេខ ០០៩៦១៧ |
| ៥១-វរសេនីយ៍ឯក | ឆាំង | មុន្នី | អត្តលេខ ០២៩២១៩ |

៥២-វរសេនីយ៍ឯក ម៉ែន ស៊ីទួន អត្តលេខ ០១៧០០២
៥៣-វរសេនីយ៍ឯក ម៉ម ប៊ិត អត្តលេខ ០០៨៦៦៧
៥៤-វរសេនីយ៍ឯក ថាច់ គួន អត្តលេខ ០០១៦៥៦
៥៥-វរសេនីយ៍ឯក សួន យ៉ីវ អត្តលេខ ០០៣៧៦៤
៥៦-វរសេនីយ៍ឯក ខាន់ ពៅ អត្តលេខ ០០១៨២៨
៥៧-វរសេនីយ៍ឯក ប៉ាវ នុត អត្តលេខ ០០៤៤៣១
៥៨-វរសេនីយ៍ឯក អ៊ុំ សុខុន អត្តលេខ ០១០១៧៨
៥៩-វរសេនីយ៍ឯក អ៊ុក ប៊ុនណ្ណា អត្តលេខ ០០១៦៩១
៦០-វរសេនីយ៍ឯក ម៉ុក សារិន អត្តលេខ ០០១៦៩៤
៦១-វរសេនីយ៍ឯក ហ៊ុច សុគុណា អត្តលេខ ០០០៦០៦
៦២-វរសេនីយ៍ឯក ព្រហ្ម វិចិត្រ អត្តលេខ ០១៤៤៨២
៦៣-វរសេនីយ៍ឯក ឡៅ ឡាំពន្លក អត្តលេខ ០០១៦៨៣
៦៤-វរសេនីយ៍ឯក ស៊ិន សេដា អត្តលេខ ០០៣១៩៧
៦៥-វរសេនីយ៍ឯក ជ័យ ផល្លុន អត្តលេខ ០០៣១៩៩
៦៦-វរសេនីយ៍ឯក ឡុង សារ៉ុន អត្តលេខ ០០៣១៩៨
៦៧-វរសេនីយ៍ឯក ទូច វិចិត្រ អត្តលេខ ០០១៤៥៧
៦៨-វរសេនីយ៍ឯក ធូ ពិទូរ អត្តលេខ ០១៤៤៨៤
៦៩-វរសេនីយ៍ឯក ខៀវ វណ្ណា អត្តលេខ ០០០៥៨៩
៧០-វរសេនីយ៍ឯក គង់ សុម៉ាឡា អត្តលេខ ០០២២៦២
៧១-វរសេនីយ៍ឯក គ្រឹង សុង អត្តលេខ ០១៣៩៣៦
៧២-វរសេនីយ៍ឯក ប៉ែន ផល្លី អត្តលេខ ០០១៥៧៧
៧៣-វរសេនីយ៍ឯក ច័ន្ទ ស៊ីថា អត្តលេខ០០៨៤២២
៧៤-វរសេនីយ៍ឯក ឡឹក សាមិន អត្តលេខ ០០៨៤១៨
៧៥-វរសេនីយ៍ឯក ទួន គួន អត្តលេខ ០០១៥៩០
៧៦-វរសេនីយ៍ឯក គង់ ផន អត្តលេខ ០០១៨២៣
៧៧-វរសេនីយ៍ឯក លឹម ពេជ្រសារ អត្តលេខ ០២៤៧៨៧
៧៨-វរសេនីយ៍ឯក ហ៊ុំ ឿ្រឿង អត្តលេខ ០០៣២៦៩
៧៩-វរសេនីយ៍ឯក សេង សុផល អត្តលេខ ០១៣៧០៣
៨០-វរសេនីយ៍ឯក ខេង ឌី អត្តលេខ ០០១៥៧៨
៨១-វរសេនីយ៍ឯក សុខ វណ្ណសាន អត្តលេខ ០០២៤៣៧
៨២-វរសេនីយ៍ឯក ង៉ែត សារិន អត្តលេខ ០០២២៧០
៨៣-វរសេនីយ៍ឯក ម៉ូត ស៊ីថា អត្តលេខ ០០៩៦២៩
៨៤-វរសេនីយ៍ឯក ងិត ចន អត្តលេខ ០០៩៦៣៩
៨៥-វរសេនីយ៍ឯក ឡុង សារ៉ន អត្តលេខ ០០៩៦២១
៨៦-វរសេនីយ៍ឯក តោគ សំអៀត អត្តលេខ ០០២២៧៣
៨៧-វរសេនីយ៍ឯក សៅ មង្គល អត្តលេខ ០១៧៦១៣
៨៨-វរសេនីយ៍ឯក យូ វិបុល អត្តលេខ ០២៧១២៤
៨៩-វរសេនីយ៍ឯក សាន្ត ថ៉ា អត្តលេខ ០០៣៨៤៦



| | | | |
|---|---|---|---|
| ៩០-វរសេនីយ៍ឯក | សំ | សុផា | អត្តលេខ ០២៧១២៧ |
| ៩១-វរសេនីយ៍ឯក | អ៊ិន | ជឿន | អត្តលេខ ០០៩០៤៧ |
| ៩២-វរសេនីយ៍ឯក | ម៉ម | ផៃ | អត្តលេខ ១៦៣២០៤ |
| ៩៣-វរសេនីយ៍ឯក | ហួត | សុខឃី | អត្តលេខ ០០២២៤៥ |
| ៩៤-វរសេនីយ៍ឯក | កុយ | សុវណ្ណា | អត្តលេខ ០០៣៨៣៧ |
| ៩៥-វរសេនីយ៍ឯក | អ៊ុំខ | សារ៉ុម | អត្តលេខ ០០៨៦៨៨ |
| ៩៦-វរសេនីយ៍ឯក | មៃ | លន | អត្តលេខ ០១៤៤២៥ |
| ៩៧-វរសេនីយ៍ឯក | ស៊ឹម | សុខា | អត្តលេខ ១៥៦៥៣៣ |
| ៩៨-វរសេនីយ៍ឯក | ជា | ចិសុធា | អត្តលេខ ០០៨៦៨៦ |
| ៩៩-វរសេនីយ៍ឯក | ចឹក | សារិន | អត្តលេខ ០១៤៣៦៦ |
| ១០០-វរសេនីយ៍ឯក | ប៉ោក | សារឿន | អត្តលេខ ០១៤៣៣៣ |
| ១០១-វរសេនីយ៍ឯក | លុយ | សុទ្ធ | អត្តលេខ ០១៤៣២៨ |
| ១០២-វរសេនីយ៍ឯក | ណុប | សាវី | អត្តលេខ ០១៤៣៣៤ |
| ១០៣-វរសេនីយ៍ឯក | ផាន់ | សុផាន | អត្តលេខ ០១៤៣៤៨ |
| ១០៤-វរសេនីយ៍ឯក | អ៊ុក | ឈុន | អត្តលេខ ០០១៤២៦ |
| ១០៥-វរសេនីយ៍ឯក | ឈឹម | សុផាន់ | អត្តលេខ ០០១៤២០ |
| ១០៦-វរសេនីយ៍ឯក | យាន | កុសល | អត្តលេខ ០០១៤៣០ |
| ១០៧-វរសេនីយ៍ឯក | គង់ | ពៅ | អត្តលេខ ០១៣៨៤២ |
| ១០៨-វរសេនីយ៍ឯក | អ៊ូ | ទីរៈ | អត្តលេខ ០១៣៨១៥ |
| ១០៩-វរសេនីយ៍ឯក | អៀង | លីន | អត្តលេខ ០០៨៥៦៨ |
| ១១០-វរសេនីយ៍ឯក | សោម | សារី | អត្តលេខ ០៤៨៥៦៥ |
| ១១១-វរសេនីយ៍ឯក | មូ | គឹមជួន | អត្តលេខ ០១៣៨៣៧ |
| ១១២-វរសេនីយ៍ឯក | យឹម | សារិន | អត្តលេខ ០០៨៥៩៨ |
| ១១៣-វរសេនីយ៍ឯក | អ៊ុំ | សារ៉ាន | អត្តលេខ ០០១៤២៥ |
| ១១៤-វរសេនីយ៍ឯក | កែវ | សុខគៀត | អត្តលេខ ០២៤៦៧៨ |
| ១១៥-វរសេនីយ៍ឯក | សម | សារឿន | អត្តលេខ ០២៤៥១៧ |
| ១១៦-វរសេនីយ៍ឯក | សារិ | ចុឌ្ឍី | អត្តលេខ ០១៣៨១៩ |
| ១១៧-វរសេនីយ៍ឯក | ជេត | កែវ | អត្តលេខ ០១៣៨៣១ |
| ១១៨-វរសេនីយ៍ឯក | អៀ | ម៉ុនណារ៉េត | អត្តលេខ ០០៨៥៦៧ |
| ១១៩-វរសេនីយ៍ឯក | គឹម | ហឿន | អត្តលេខ ០១៣៨១២ |
| ១២០-វរសេនីយ៍ឯក | សូ | ស៊ុនណារី | អត្តលេខ ០២៥២៧២ |
| ១២១-វរសេនីយ៍ឯក | ម៉ៅ | ស៊ីផា | អត្តលេខ ០២៥១៣៥ |
| ១២២-វរសេនីយ៍ឯក | ហង្ស | សន | អត្តលេខ ០០៨៥៩៣ |
| ១២៣-វរសេនីយ៍ឯក | ស្រី | ស៊ីជេត | អត្តលេខ ០១៤០៥២ |
| ១២៤-វរសេនីយ៍ឯក | ប៉ា | ណារ៉ុន | អត្តលេខ ០២៤៦៤១ |
| ១២៥-វរសេនីយ៍ឯក | គង់ | សោភ័ណ្ឌ | អត្តលេខ ០០៨៤៥៧ |
| ១២៦-វរសេនីយ៍ឯក | ច័ន្ទ | សុវណ្ណា | អត្តលេខ ០០៨៤៤៤ |
| ១២៧-វរសេនីយ៍ឯក | ចាន់ | បូរិន្ទ | អត្តលេខ ០០១៤៨១ |

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

១២៨-វរសេនីយ៍ឯក សឹង សុខុម អត្តលេខ ០០១៤៧៨
១២៩-វរសេនីយ៍ឯក អ៊ឹម មុន្នីរត្ន័ អត្តលេខ ០២០៦៤៣
១៣០-វរសេនីយ៍ឯក ណំ សុជ័យ អត្តលេខ ០០៣១៨២
១៣១-វរសេនីយ៍ឯក ស៊ឹម សំអឿន អត្តលេខ ០៤៣៨៩៦
១៣២-វរសេនីយ៍ឯក ខៀវ គន្ធី អត្តលេខ ០០១៦៦៤
១៣៣-វរសេនីយ៍ឯក ទេព ឬទី អត្តលេខ ០១៤២៣២
១៣៤-វរសេនីយ៍ឯក សុខ សារឿន អត្តលេខ ០០១៦៨០
១៣៥-វរសេនីយ៍ឯក ចាន់ សេដ្ឋា អត្តលេខ ០០១៤៥១
១៣៦-វរសេនីយ៍ឯក ហួន វណ្ណឌី អត្តលេខ ០១៧១៧៨
១៣៧-វរសេនីយ៍ឯក ចាន់ ផេង អត្តលេខ ០០១៧៤៤
១៣៨-វរសេនីយ៍ឯក ម៉ែន មុន្នី អត្តលេខ ០០១៦០០
១៣៩-វរសេនីយ៍ឯក រត្ន័ សារុន អត្តលេខ ០០៨៤៨៦
១៤០-វរសេនីយ៍ឯក អ៊ុន សំអន អត្តលេខ ០០១៦០២
១៤១-វរសេនីយ៍ឯក គង់ គឹមអេង អត្តលេខ ០២៦០៣៣
១៤២-វរសេនីយ៍ឯក ប៉ាត យ៉ាន អត្តលេខ ០០២១៦១
១៤៣-វរសេនីយ៍ឯក ជាតិ ប៉ាវ អត្តលេខ ០០០៩៩៣
១៤៤-វរសេនីយ៍ឯក ចាច់ សារ៉ាវុឌ្ឍ អត្តលេខ ០០៣២៣១
១៤៥-វរសេនីយ៍ឯក ចាន់ បូរី អត្តលេខ ០០៣៥៣០
១៤៦-វរសេនីយ៍ឯក សំ វត្ថា អត្តលេខ ០០៩៤៧០
១៤៧-វរសេនីយ៍ឯក សម ឆន្ទ អត្តលេខ ០០៩៤៦៨
១៤៨-វរសេនីយ៍ឯក លី ជឿន អត្តលេខ ០០៣២៥៦
១៤៩-វរសេនីយ៍ឯក សួន សុគុម អត្តលេខ ០០៨៩៤១
១៥០-វរសេនីយ៍ឯក ញ៉ៀម សារ៉ែន អត្តលេខ ០០២២៩៩
១៥១-វរសេនីយ៍ឯក មាស សុក្រ អត្តលេខ ០០៣៤០៩
១៥២-វរសេនីយ៍ឯក យឹម កុសល អត្តលេខ ០០៣២៨២
១៥៣-វរសេនីយ៍ឯក សេង ម៉ុនធឿន អត្តលេខ ០០៣៤២០
១៥៤-វរសេនីយ៍ឯក អ៊ាំ នាង អត្តលេខ ០០៣៤១៤
១៥៥-វរសេនីយ៍ឯក ប្រាក់ ផាន់ណារ៉ា អត្តលេខ ០០៣៤០៣
១៥៦-វរសេនីយ៍ឯក សូ ស៊ីផន អត្តលេខ ០០៣២៨០
១៥៧-វរសេនីយ៍ឯក ជា កែវសុធី អត្តលេខ ០១៥៤៧១
១៥៨-វរសេនីយ៍ឯក គុយ សុគន្ធី អត្តលេខ ០១៨៣២០
១៥៩-វរសេនីយ៍ឯក ហ៊ឹម សុផុន អត្តលេខ ០១៦៤៧៨
១៦០-វរសេនីយ៍ឯក កុយ ឡុងឈាង អត្តលេខ ០០១៨៩៧
១៦១-វរសេនីយ៍ឯក សៅ ផេង អត្តលេខ ០១៦៨៦៥
១៦២-វរសេនីយ៍ឯក សៀ សំអុន អត្តលេខ ០១៧២៣៧
១៦៣-វរសេនីយ៍ឯក អង់ សារិទ្ធ អត្តលេខ ០០៣៨៦៤
១៦៤-វរសេនីយ៍ឯក ស៊ុំ អ៊ាង អត្តលេខ ០០៣៥៦១
១៦៥-វរសេនីយ៍ឯក យន វឌ្ឍនៈ អត្តលេខ ០០៣៣១១

១៦៦-វរសេនីយ៍ឯក ម៉ៅ ម៉ារិន អត្តលេខ ០២១៧៦២
១៦៧-វរសេនីយ៍ឯក ជា ផានី អត្តលេខ ០០៩០៥៩
១៦៨-វរសេនីយ៍ឯក ពុទ្ធ ឌុន្សី អត្តលេខ ០០២៥៤៦
១៦៩-វរសេនីយ៍ឯក ឱរ សូរិយា អត្តលេខ ០០២៥៨៩
១៧០-វរសេនីយ៍ឯក សេក សាម៉ន អត្តលេខ ០០៣០៨០
១៧១-វរសេនីយ៍ឯក ទឹម សារ៉េត អត្តលេខ ០១១៩៩៥
១៧២-វរសេនីយ៍ឯក ទុន ឡៀត អត្តលេខ ០១០៥៤៤
១៧៣-វរសេនីយ៍ឯក តូច សុផាត អត្តលេខ ០១០៦៨៣
១៧៤-វរសេនីយ៍ឯក ហ៊ុយ គឹមឃន អត្តលេខ ០០២១១៦
១៧៥-វរសេនីយ៍ឯក ឃុន សាម៉ែខ អត្តលេខ ០១២៣៥៩
១៧៦-វរសេនីយ៍ឯក អៀម អ៊ូក អត្តលេខ ០០៨៨០៦
១៧៧-វរសេនីយ៍ឯក ដូ ឌួនហេង អត្តលេខ ០០២៧៨១
១៧៨-វរសេនីយ៍ឯក ចាប ទិសុទ្ធ អត្តលេខ ០០១៩៩២
១៧៩-វរសេនីយ៍ឯក អ៊ឹម សម្បត្តិ អត្តលេខ ០១៦៦២៦
១៨០-វរសេនីយ៍ឯក ថ្លាង បូរាណា អត្តលេខ ០០៨៨៤២
១៨១-វរសេនីយ៍ឯក លី ជិនលាង អត្តលេខ ០០២៦១៧
១៨២-វរសេនីយ៍ឯក កែវ សារី អត្តលេខ ០១២៦៣០
១៨៣-វរសេនីយ៍ឯក មូ ខ៉ាន់ធឿន អត្តលេខ ០០៣៥៩៩
១៨៤-វរសេនីយ៍ឯក ឡៀង ពៅ អត្តលេខ ០០៣៥២៤
១៨៥-វរសេនីយ៍ឯក ខ៉ាន់ សារិទ្ធ អត្តលេខ ០០៣៦០១
១៨៦-វរសេនីយ៍ឯក យន្ត ដឹក អត្តលេខ ០០៣៦០០
១៨៧-វរសេនីយ៍ឯក ព្រហ្ម សារី អត្តលេខ ០០៣៥៦៧
១៨៨-វរសេនីយ៍ឯក រស់ សំអុល អត្តលេខ ០០១២៤៩
១៨៩-វរសេនីយ៍ឯក គល់ សេង អត្តលេខ ០០៣៥២៨
១៩០-វរសេនីយ៍ឯក ហួរ សារ៉េត អត្តលេខ ០០៤៣៨៨
១៩១-វរសេនីយ៍ឯក ស្រស់ សុខុម អត្តលេខ ០០១២៦០
១៩២-វរសេនីយ៍ឯក សំ រិន អត្តលេខ ០០១៣៥៣
១៩៣-វរសេនីយ៍ឯក មិន សុវ៉ុយ អត្តលេខ ០០៣៥៦២
១៩៤-វរសេនីយ៍ឯក អ៊ុង ថូ អត្តលេខ ០០២២០៧
១៩៥-វរសេនីយ៍ឯក រិទ្ធ បូរីយ៍ អត្តលេខ ០០៣២៦៤
១៩៦-វរសេនីយ៍ឯក ពុម្ព ស្អាត អត្តលេខ ០១៧៧៦០
១៩៧-វរសេនីយ៍ឯក សែម សុវណ្ណា អត្តលេខ ០០២២៦០
១៩៨-វរសេនីយ៍ឯក ឯក សេនា អត្តលេខ ០០៥១៤៧
១៩៩-វរសេនីយ៍ឯក ញ៉ឹម ស្រេង អត្តលេខ ០១៤៦១០
២០០-វរសេនីយ៍ឯក នុត សាមឿន អត្តលេខ ០០៣២៥៥
២០១-វរសេនីយ៍ឯក ជ័យ គឹមសារី អត្តលេខ ០០៩៥៨២
២០២-វរសេនីយ៍ឯក ជា ជុន អត្តលេខ ០១៧៦៨៧
២០៣-វរសេនីយ៍ឯក ជា ណាន អត្តលេខ ០០១៩៥២

២០៤-វរសេនិយ៍ឯក ទឹម សារឿន អត្តលេខ ០០៤៩៤២
២០៥-វរសេនីយ៍ឯក អេង ផាន់ អត្តលេខ ០០៣៤២៨
២០៦-វរសេនីយ៍ឯក គង់ សុផល អត្តលេខ ០០៩០៩៤
២០៧-វរសេនីយ៍ឯក តុល ម៉ង់ឌី អត្តលេខ ០១២៥៧៤
២០៨-វរសេនីយ៍ឯក ឈឹម ឈឿន អត្តលេខ ០១៧០០០
២០៩-វរសេនីយ៍ឯក ពុធ រដ្ឋា អត្តលេខ ០០៩០២៩
២១០-វរសេនីយ៍ឯក គួ ចំណាប់ អត្តលេខ ០១៧២២៩
២១១-វរសេនីយ៍ឯក ម៉ៅ ស្ទឹគ អត្តលេខ ០០៣៤១២
២១២-វរសេនីយ៍ឯក សេង សាម៉ុន អត្តលេខ ០០១៩៤៣
២១៣-វរសេនីយ៍ឯក ហ៊ិន ម៉ុនធី អត្តលេខ ០០៨៧៩៦
២១៤-វរសេនីយ៍ឯក ឡាំ ថាញ់ អត្តលេខ ០១២០២៥
២១៥-វរសេនីយ៍ឯក ចាន់ ធី អត្តលេខ ០០៤១៥៦
២១៦-វរសេនីយ៍ឯក សំ ម៉ាន់ អត្តលេខ ០១៦៩៩៥
២១៧-វរសេនីយ៍ឯក ស៊ុយ ចាន់ឃីពុន អត្តលេខ ០០២២៥៦
២១៨-វរសេនីយ៍ឯក អ៊ុក សារុន អត្តលេខ ០០២១៦៥
២១៩-វរសេនីយ៍ឯក ញ៉ឹក ពិសិដ្ឋ អត្តលេខ ០០៩៦៨៦
២២០-វរសេនីយ៍ឯក ខ៉ាន់ អឿន អត្តលេខ ០១៧៨៦៧
២២១-វរសេនីយ៍ឯក អន រួម អត្តលេខ ០១៧៨៥១
២២២-វរសេនីយ៍ឯក ណោត លីន អត្តលេខ ០០៩៦៧៨
២២៣-វរសេនីយ៍ឯក នុត មុយ អត្តលេខ ០០៩៦៧៥
២២៤-វរសេនីយ៍ឯក ឃឿន សីហា អត្តលេខ ០០៩៦៧៩
២២៥-វរសេនីយ៍ឯក ឈឿម ថា អត្តលេខ ០០៩៦៦៩
២២៦-វរសេនីយ៍ឯក ណាម ស៊ីណាត អត្តលេខ ០១៧៨១៧
២២៧-វរសេនីយ៍ឯក ទៀម ស៊ីន អត្តលេខ ០១៧៨១៥
២២៨-វរសេនីយ៍ឯក សុខ ចាន់សារិន អត្តលេខ ០២៧៦០៦
២២៩-វរសេនីយ៍ឯក រស់ សាខ៉ាត អត្តលេខ ០០៩៦៦០
២៣០-វរសេនីយ៍ឯក សួន គីម អត្តលេខ ០១៧៨៥៦
២៣១-វរសេនីយ៍ឯក សា គឹមសាន្ត អត្តលេខ ០០៩៦៤៨
២៣២-វរសេនីយ៍ឯក ម៉ែន ធីវ អត្តលេខ ០២៧៦៣៦
២៣៣-វរសេនីយ៍ឯក ប្រាក់ ចន្ធី អត្តលេខ ០០២៣១៣
២៣៤-វរសេនីយ៍ឯក គង់ គីម អត្តលេខ ០០៩៦៤៤
២៣៥-វរសេនីយ៍ឯក សៅ សារិទ្ធ អត្តលេខ ០១៧៨៣១
២៣៦-វរសេនីយ៍ឯក ស៊ុន សន អត្តលេខ ០១៧១២៤
២៣៧-វរសេនីយ៍ឯក តឹក ចន្ទ័ អត្តលេខ ០០៨៨៥២
២៣៨-វរសេនីយ៍ឯក ស៊ុយ ប្រាក់ អត្តលេខ ០១៧៨២៩
២៣៩-វរសេនីយ៍ឯក ឆេង លីវ អត្តលេខ ០១៤៤៨៧
២៤០-វរសេនីយ៍ឯក សំរិទ្ធ សុខុម អត្តលេខ ០០២៤៣៨
២៤១-វរសេនីយ៍ឯក ឈួន ទីវ៉ែម អត្តលេខ ០០៩៦៦៣

ROYAUME DU CAMBODGE ... MINISTRE DU PALAIS ROYAL

| | | | |
|---|---|---|---|
| ២៤២-វរសេនីយ៍ឯក | ម៉ិន | ធឿន | អត្តលេខ ០០២២២៦ |
| ២៤៣-វរសេនីយ៍ឯក | ទេព | ជួប | អត្តលេខ ០០៩១៩៩ |
| ២៤៤-វរសេនីយ៍ឯក | អ៊ុក | ចាន់ឌឿន | អត្តលេខ ០០៩២០៣ |
| ២៤៥-វរសេនីយ៍ឯក | អ៊ីម | សារ៉ាត | អត្តលេខ ០០៩០៨៦ |
| ២៤៦-វរសេនីយ៍ឯក | ជរ | គឹមយ៉េង | អត្តលេខ ០០៩០៨៥ |
| ២៤៧-វរសេនីយ៍ឯក | អ៊ុន | ឧត្តី | អត្តលេខ ០១៧១១៩ |
| ២៤៨-វរសេនីយ៍ឯក | ចាន់ | សំអាន | អត្តលេខ ០១៧១៣៣ |
| ២៤៩-វរសេនីយ៍ឯក | ឆុក | ទ្រី | អត្តលេខ ០១៧១២៧ |
| ២៥០-វរសេនីយ៍ឯក | ឡុច | ដារុធ | អត្តលេខ ០៤៤៩៩៧ |
| ២៥១-វរសេនីយ៍ឯក | គួក | គន្ធារ | អត្តលេខ ០០៩០៧៤ |
| ២៥២-វរសេនីយ៍ឯក | ស៊ិន | សារឹម | អត្តលេខ ០០៩៣៨៥ |
| ២៥៣-វរសេនីយ៍ឯក | គង់ | សម្បត្តិ | អត្តលេខ ០១៧៣១៣ |
| ២៥៤-វរសេនីយ៍ឯក | សៀង | ស៊ីធឿន | អត្តលេខ ០០៩៣៨៤ |
| ២៥៥-វរសេនីយ៍ឯក | រាម | សាលី | អត្តលេខ ០១៧២៨៩ |
| ២៥៦-វរសេនីយ៍ឯក | ស៊ុំ | សួយ | អត្តលេខ ០១៧២៩៤ |
| ២៥៧-វរសេនីយ៍ឯក | សុខ | ចាន់ថុល | អត្តលេខ ០០៩៣៧៤ |
| ២៥៨-វរសេនីយ៍ឯក | តៀក | សរ | អត្តលេខ ០១៧៣៦៣ |
| ២៥៩-វរសេនីយ៍ឯក | អ៊ុក | សៀន | អត្តលេខ ០១៩៣៤១ |
| ២៦០-វរសេនីយ៍ឯក | គឹម | នូ | អត្តលេខ ០០៩៣៧៩ |
| ២៦១-វរសេនីយ៍ឯក | ម៉ក់ | ម៉ៃ | អត្តលេខ ០១៧៣៤៣ |
| ២៦២-វរសេនីយ៍ឯក | ចៅ | ម៉ុច | អត្តលេខ ០០៩៣៨៣ |
| ២៦៣-វរសេនីយ៍ឯក | សៅ | សុខុន | អត្តលេខ ០១៧៣៩២ |
| ២៦៤-វរសេនីយ៍ឯក | ឡុង | សុខហាន | អត្តលេខ ០១៧៤០៤ |
| ២៦៥-វរសេនីយ៍ឯក | ជា | សាលីម | អត្តលេខ ០០៩៤១៨ |
| ២៦៦-វរសេនីយ៍ឯក | ហាក្យ | សុខុម | អត្តលេខ ០២៦៨៩១ |
| ២៦៧-វរសេនីយ៍ឯក | គង់ | ធី | អត្តលេខ ០០៩៤០៣ |
| ២៦៨-វរសេនីយ៍ឯក | ឌិន | សាមឿន | អត្តលេខ ០១៧៤០២ |
| ២៦៩-វរសេនីយ៍ឯក | គង់ | សុខតំណ្ណា | អត្តលេខ ០០៨៥៧៤ |
| ២៧០-វរសេនីយ៍ឯក | រិន | សារ៉ន | អត្តលេខ ០០៩៥១០ |
| ២៧១-វរសេនីយ៍ឯក | ម៉ែន | មិថុល | អត្តលេខ ០០៩៥១៧ |
| ២៧២-វរសេនីយ៍ឯក | កែម | សឿន | អត្តលេខ ១៤៩៩៩២ |
| ២៧៣-វរសេនីយ៍ឯក | សូ | សារិន | អត្តលេខ ០១៧៧៤៧ |
| ២៧៤-វរសេនីយ៍ឯក | ទ្រុំ | ពៅ | អត្តលេខ ០២៤៤៨៩ |
| ២៧៥-វរសេនីយ៍ឯក | អ៊ុក | សាខន | អត្តលេខ ០១៩១០២ |
| ២៧៦-វរសេនីយ៍ឯក | អ៊ុក | អូន | អត្តលេខ ០១០០០៧ |
| ២៧៧-វរសេនីយ៍ឯក | ស៊ឹម | រៀម | អត្តលេខ ០១៩១៣៧ |
| ២៧៨-វរសេនីយ៍ឯក | ម៉ុត | ហុក | អត្តលេខ ០១០០១២ |
| ២៧៩-វរសេនីយ៍ឯក | មឿន | គង់ | អត្តលេខ ០១៩០៦០ |

២៨០-វរសេនីយ៍ឯក ថាច់ ស្វារ៉េន អត្តលេខ ០១០០១១
២៨១-វរសេនីយ៍ឯក ជុំ ផាន អត្តលេខ ០០៤២០៤
២៨២-វរសេនីយ៍ឯក ជា សុវណ្ណា អត្តលេខ ០១៨០០៨
២៨៣-វរសេនីយ៍ឯក ឈិន ប៊ុនឆន អត្តលេខ ០១១៥០២
២៨៤-វរសេនីយ៍ឯក ម៉ៅ សំអុន អត្តលេខ ០០២២៩២
២៨៥-វរសេនីយ៍ឯក កែវ រឿន អត្តលេខ ០០២២៩៥
២៨៦-វរសេនីយ៍ឯក គង់ ច័ន្ទវិជ្ជីរ អត្តលេខ ០០៩២៣៥
២៨៧-វរសេនីយ៍ឯក ទូច តាត អត្តលេខ ០០២២៨២
២៨៨-វរសេនីយ៍ឯក ដាំ ឆន អត្តលេខ ០០៤៨៤២
២៨៩-វរសេនីយ៍ឯក វ័ល វិរៈសង្គ្រាម អត្តលេខ ០០៩០៦៦
២៩០-វរសេនីយ៍ឯក ឈឹម ណុល អត្តលេខ ០០២៣៤៥
២៩១-វរសេនីយ៍ឯក ភឿន វិន អត្តលេខ ០១០៩៤៣
២៩២-វរសេនីយ៍ឯក ម៉ិច សុវណ្ណា អត្តលេខ ០០២៣៦៧
២៩៣-វរសេនីយ៍ឯក ហាក់ សុគន្ធារី អត្តលេខ ០៥៦២៦៤
២៩៤-វរសេនីយ៍ឯក អ៊ាន់ វ៉ុនណាយ អត្តលេខ ០០១៩៥៨
២៩៥-វរសេនីយ៍ឯក សាម មឿយ អត្តលេខ ០០១៨៩៨
២៩៦-វរសេនីយ៍ឯក ម៉ា ពុទ្ធី អត្តលេខ ០០១៨៨២
២៩៧-វរសេនីយ៍ឯក សៀង អំរ៉ូ អត្តលេខ ០០៨៩៣៤
២៩៨-វរសេនីយ៍ឯក មាស ធឿន អត្តលេខ ០០៩៤៤១
២៩៩-វរសេនីយ៍ឯក អ៊ូ ស៊ុន អត្តលេខ ០០៣១៧១
៣០០-វរសេនីយ៍ឯក ជា ម៉េង អត្តលេខ ០០២០៥៧
៣០១-វរសេនីយ៍ឯក ជា សុវត្ថា អត្តលេខ ០០៨៩៤៧
៣០២-វរសេនីយ៍ឯក លឿង សារិន អត្តលេខ ០១៦៧៥៩
៣០៣-វរសេនីយ៍ឯក ដួង ផ្លា អត្តលេខ ០០៣៤៩៦
៣០៤-វរសេនីយ៍ឯក ហេង សុខា អត្តលេខ ០០៤២២៩
៣០៥-វរសេនីយ៍ឯក ឡុង វណ្ណះ អត្តលេខ ០០៨៧៤៧
៣០៦-វរសេនីយ៍ឯក ម៉ិញ ខេម៉ា អត្តលេខ ០០៨៧៤៦
៣០៧-វរសេនីយ៍ឯក យូ ប៊ូកេន អត្តលេខ ០២៩៨៧៣
៣០៨-វរសេនីយ៍ឯក ឡុក សំអាត អត្តលេខ ០១៦៧២២
៣០៩-វរសេនីយ៍ឯក ឡាយ ថាត អត្តលេខ ០១៧០២៣
៣១០-វរសេនីយ៍ឯក ទុំ អេង អត្តលេខ ០១៩៧៣៧
៣១១-វរសេនីយ៍ឯក សុខ សាវន អត្តលេខ ០៨២២៣២
៣១២-វរសេនីយ៍ឯក ដួង សុភឿន អត្តលេខ ០០៩៥៦៧
៣១៣-វរសេនីយ៍ឯក និត្យ សុជាតិ អត្តលេខ ០០៩៥៥៨
៣១៤-វរសេនីយ៍ឯក ចាន់ សុផល អត្តលេខ ០១៧៦០១
៣១៥-វរសេនីយ៍ឯក នូ សុវណ្ណារា អត្តលេខ ០១៧៦១០
៣១៦-វរសេនីយ៍ឯក ម៉ិច ប៊ុនហួរ អត្តលេខ ០០៩៥៥០
៣១៧-វរសេនីយ៍ឯក មុត សាត អត្តលេខ ០១៧៣០០



| | | | |
|---|---|---|---|
| ៣១៨-វរសេនីយ៍ឯក | យិន | ឈន | អត្តលេខ ០១៧៣៤៤ |
| ៣១៩-វរសេនីយ៍ឯក | ព្រួ | សារ៉ាន់ | អត្តលេខ ០១៨២០៩ |
| ៣២០-វរសេនីយ៍ឯក | ច័ន្ទ | ហាន | អត្តលេខ ០១៥៩០៤ |
| ៣២១-វរសេនីយ៍ឯក | សួរ | សារិទ្ធ | អត្តលេខ ០០៩០៨៣ |
| ៣២២-វរសេនីយ៍ឯក | ឈឿម | សុខលី | អត្តលេខ ០១៧១១០ |
| ៣២៣-វរសេនីយ៍ឯក | មាស | សុធី | អត្តលេខ ០០៩៦៨៩ |
| ៣២៤-វរសេនីយ៍ឯក | ហោខ | សុខចេខ | អត្តលេខ ០០៩៤៤៤ |
| ៣២៥-វរសេនីយ៍ឯក | ទួន | វិបុល | អត្តលេខ ០០២២៥៧ |
| ៣២៦-វរសេនីយ៍ឯក | ទុត | ម៉ាប់ | អត្តលេខ ០០២៣១១ |
| ៣២៧-វរសេនីយ៍ឯក | សែត | សុខុម | អត្តលេខ ០០២៣០៨ |
| ៣២៨-វរសេនីយ៍ឯក | សុខ | សូវ៉ាត | អត្តលេខ ០០៩៣៥២ |
| ៣២៩-វរសេនីយ៍ឯក | ចិន | សាវី | អត្តលេខ ០០៩៣៣៦ |
| ៣៣០-វរសេនីយ៍ឯក | ស៊ិន | សំអឿន | អត្តលេខ ០០៣៣៨៨ |
| ៣៣១-វរសេនីយ៍ឯក | គូ | ម៉ិត | អត្តលេខ ០០៩៣៤៨ |
| ៣៣២-វរសេនីយ៍ឯក | ឱន | ថា | អត្តលេខ ០០៣១១០ |
| ៣៣៣-វរសេនីយ៍ឯក | ម៊ុន | ទី | អត្តលេខ ០០២៦៧៩ |
| ៣៣៤-វរសេនីយ៍ឯក | ខេង | សារុន | អត្តលេខ ០០២៧៧០ |
| ៣៣៥-វរសេនីយ៍ឯក | ឯក | ចេត្តនា | អត្តលេខ ០០២៦៨៣ |
| ៣៣៦-វរសេនីយ៍ឯក | ថា | ថងឡៀន | អត្តលេខ ០០៤៩៥៩ |
| ៣៣៧-វរសេនីយ៍ឯក | មាស | គីមសុត្រា | អត្តលេខ ០០៩៧២៩ |
| ៣៣៨-វរសេនីយ៍ឯក | ឈាន | បូរិន្ទ | អត្តលេខ ០០២៦៧៧ |
| ៣៣៩-វរសេនីយ៍ឯក | ទ្រី | សំរិទ្ធ | អត្តលេខ ០១៨៣៧៨ |
| ៣៤០-វរសេនីយ៍ឯក | កែវ | សុវណ្ណា | អត្តលេខ ០១៨៣៨៧ |
| ៣៤១-វរសេនីយ៍ឯក | អ៊ិន | សួនធីន | អត្តលេខ ០០២៦៨៧ |
| ៣៤២-វរសេនីយ៍ឯក | ម៉ុក | សុភារិទ្ធ | អត្តលេខ ០១៩៩៩១ |
| ៣៤៣-វរសេនីយ៍ឯក | ដោក | បូណា | អត្តលេខ ០០២៦៨០ |
| ៣៤៤-វរសេនីយ៍ឯក | ស្រី | ឡម | អត្តលេខ ០០៩៧៤៤ |
| ៣៤៥-វរសេនីយ៍ឯក | ញឹម | សុវណ្ណា | អត្តលេខ ០០០៨៩៥ |
| ៣៤៦-វរសេនីយ៍ឯក | ធិន | សៅ | អត្តលេខ ០០២៧៤០ |
| ៣៤៧-វរសេនីយ៍ឯក | យី | សំណាង | អត្តលេខ ០០២៧៣៨ |
| ៣៤៨-វរសេនីយ៍ឯក | ឡាង | សាឡឿន | អត្តលេខ ០០២៧១៥ |
| ៣៤៩-វរសេនីយ៍ឯក | ម៉ៅ | ឡា | អត្តលេខ ០០០៩២០ |
| ៣៥០-វរសេនីយ៍ឯក | អ៊ិន | វិសាខ | អត្តលេខ ០០១១៥៥ |
| ៣៥១-វរសេនីយ៍ឯក | មួង | សម្បត្តិ | អត្តលេខ ០០២៧១៦ |
| ៣៥២-វរសេនីយ៍ឯក | គុជ | ដាវី | អត្តលេខ ០០២៧៤៤ |
| ៣៥៣-វរសេនីយ៍ឯក | ហាំ | សុខា | អត្តលេខ ០០៩៨២៣ |
| ៣៥៤-វរសេនីយ៍ឯក | ទួន | តន | អត្តលេខ ០១៨៦២០ |
| ៣៥៥-វរសេនីយ៍ឯក | គឹម | ម៉ុន | អត្តលេខ ០០៩៨៣៥ |

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

៣៥៦-វរសេនីយ៍ឯក ពេជ្រ សារិទ្ធ អត្តលេខ ០០១០៤១

៣៥៧-វរសេនីយ៍ឯក សេខ សារី អត្តលេខ ០០២៨០២

៣៥៨-វរសេនីយ៍ឯក ញ៉ែម ឡុង អត្តលេខ ០១០៤៣៤

៣៥៩-វរសេនីយ៍ឯក ស៊ិន មឿន អត្តលេខ ០០២៧៩៦

៣៦០-វរសេនីយ៍ឯក យឹម សុផល អត្តលេខ ០០២៧៨៦

៣៦១-វរសេនីយ៍ឯក ផុន ឆាម អត្តលេខ ០០២៧៧៤

៣៦២-វរសេនីយ៍ឯក មាស សាឡឿន អត្តលេខ ០០២៨០៦

៣៦៣-វរសេនីយ៍ឯក អ៊ួន សំបូរ អត្តលេខ ០១២៣៥១

៣៦៤-វរសេនីយ៍ឯក ជុច សាឃន អត្តលេខ ០១០៥៨១

៣៦៥-វរសេនីយ៍ឯក អ៊ួន សារុំ អត្តលេខ ០០២៨០៧

៣៦៦-វរសេនីយ៍ឯក ជួន នាង អត្តលេខ ០០២៧៩៧

៣៦៧-វរសេនីយ៍ឯក ជី គឹមហាក់ អត្តលេខ ០១០៥៦២

៣៦៨-វរសេនីយ៍ឯក ហួន ឡឿន អត្តលេខ ០១០៥៥៧

៣៦៩-វរសេនីយ៍ឯក រស់ សារិន អត្តលេខ ០០២៨៧១

៣៧០-វរសេនីយ៍ឯក ជា ចាន់ថា អត្តលេខ ០១៩០០០

៣៧១-វរសេនីយ៍ឯក អ៊ួន សុផៃ អត្តលេខ ០១០៣១៥

៣៧២-វរសេនីយ៍ឯក មាស សេដ្ឋា អត្តលេខ ០១៩០៣៩

៣៧៣-វរសេនីយ៍ឯក ខាន់ សឿន អត្តលេខ ០០៤១៩៨

៣៧៤-វរសេនីយ៍ឯក សំ សឹម អត្តលេខ ០០២៨៧៨

៣៧៥-វរសេនីយ៍ឯក ហ៊ាន ចែម អត្តលេខ ០១៨៩៨០

៣៧៦-វរសេនីយ៍ឯក ចាន់ ហាន អត្តលេខ ០២៩៤៥៣

៣៧៧-វរសេនីយ៍ឯក ចេក ម៉ាច អត្តលេខ ០០៩៩៩១

៣៧៨-វរសេនីយ៍ឯក ឈឹម ឈី អត្តលេខ ០០៩៩៩៣

៣៧៩-វរសេនីយ៍ឯក ឆាន ចំរើន អត្តលេខ ០០៩៩៩៧

៣៨០-វរសេនីយ៍ឯក ឃុន ស៊ុន អត្តលេខ ០០៤៤២២

៣៨១-វរសេនីយ៍ឯក សន អ៊ាន់ អត្តលេខ ០១០០៧២

៣៨២-វរសេនីយ៍ឯក ប៊ិន សារ៉ែន អត្តលេខ ០១០៥៨៩

៣៨៣-វរសេនីយ៍ឯក ដួង សុខសារិន អត្តលេខ ០១០៦២៥

៣៨៤-វរសេនីយ៍ឯក ថាន់ សុវណ្ណា អត្តលេខ ០១០៦៣៩

៣៨៥-វរសេនីយ៍ឯក អាន សារ៉ាយ អត្តលេខ ០០១៣៩១

៣៨៦-វរសេនីយ៍ឯក អឿន អេង អត្តលេខ ០១០៦១០

៣៨៧-វរសេនីយ៍ឯក ម៉ែន សារឿន អត្តលេខ ០០៣០២៨

៣៨៨-វរសេនីយ៍ឯក អ៊ុក សត្ថា អត្តលេខ ០១៥៧៧០

៣៨៩-វរសេនីយ៍ឯក រស់ ប៊ុនហោម អត្តលេខ ០០៣៤៩៨

៣៩០-វរសេនីយ៍ឯក ប៊ុន ច័ន្ទមុន្នី អត្តលេខ ០១០៦០៩

៣៩១-វរសេនីយ៍ឯក ម៉ឹង ម៉ៅ អត្តលេខ ០០៥១៤២

៣៩២-វរសេនីយ៍ឯក គឹប ហួង អត្តលេខ ០០៣១២៦

៣៩៣-វរសេនីយ៍ឯក ផាត់ សាលី អត្តលេខ ០១០៨៩៧

៣៩៤-វរសេនីយ៍ឯក ជា សាមឿន អត្តលេខ ០១០១៣៨
៣៩៥-វរសេនីយ៍ឯក ម៉ម ស៊ីណាន អត្តលេខ ០១៥៨១៤
៣៩៦-វរសេនីយ៍ឯក ឆេង ធី អត្តលេខ ០០៣០៦៥
៣៩៧-វរសេនីយ៍ឯក ណុប វណ្ណះ អត្តលេខ ០០៣១៤៨
៣៩៨-វរសេនីយ៍ឯក ធិត្យ សារិទ្ធ អត្តលេខ ០០៣១៨០
៣៩៩-វរសេនីយ៍ឯក គឹម សុលីតារា អត្តលេខ ០០២១២០
៤០០-វរសេនីយ៍ឯក យឹម សាវុធ អត្តលេខ ០០៣១៨១
៤០១-វរសេនីយ៍ឯក ហេង សុផល អត្តលេខ ០០០៨៥៨
៤០២-វរសេនីយ៍ឯក ពូក ម៉ុនធឿន អត្តលេខ ០០៣១៦៣
៤០៣-វរសេនីយ៍ឯក ភង ម៉ុនធឿន អត្តលេខ ០១០៣៦១
៤០៤-វរសេនីយ៍ឯក គឹម ហួន អត្តលេខ ០០៥២១៨
៤០៥-វរសេនីយ៍ឯក ពៅ វុឌ្ឍី អត្តលេខ ០១០៣៥៩
៤០៦-វរសេនីយ៍ឯក ឆន សុគន្ធ អត្តលេខ ០០៤១៧៩
៤០៧-វរសេនីយ៍ឯក គង់ សវត្ថា អត្តលេខ ០០៣៤៧១
៤០៨-វរសេនីយ៍ឯក នុត ម៉ៅ អត្តលេខ ០០២៤៨៧
៤០៩-វរសេនីយ៍ឯក ឡើង សុផាន្នី អត្តលេខ ០១៨២២៣
៤១០-វរសេនីយ៍ឯក ជា សាមឿន អត្តលេខ ០០២៤២៩
៤១១-វរសេនីយ៍ឯក ជា ថូ អត្តលេខ ០០២៤៨៩
៤១២-វរសេនីយ៍ឯក ភួយ ថា អត្តលេខ ០០៩១៧៤
៤១៣-វរសេនីយ៍ឯក ញ៉ៀម វិសុទ្ធ អត្តលេខ ០០៤៦៤៤
៤១៤-វរសេនីយ៍ឯក ឡាយ តន អត្តលេខ ០០២៤៦៨
៤១៥-វរសេនីយ៍ឯក កែវ វណ្ណាណូ អត្តលេខ ០១៨២២៦
៤១៦-វរសេនីយ៍ឯក អ៊ុយ គឹមស៊ាន អត្តលេខ ០០២៤២៧
៤១៧-វរសេនីយ៍ឯក ម៉ែន សារ៉ែន អត្តលេខ ០០២៤២៣
៤១៨-វរសេនីយ៍ឯក ផាត់ សាវុធ អត្តលេខ ០២៣៣៦៧
៤១៩-វរសេនីយ៍ឯក ទេព ឡឿន អត្តលេខ ០២៣៤៤៥
៤២០-វរសេនីយ៍ឯក ម៉ុន សំអាត អត្តលេខ ០២៣៣០០
៤២១-វរសេនីយ៍ឯក សៅ សោភា អត្តលេខ ០២៩៩៧
៤២២-វរសេនីយ៍ឯក ប៉ោ សុវណ្ណា អត្តលេខ ០០១៧៧២
៤២៣-វរសេនីយ៍ឯក ម៊ូ ផុន អត្តលេខ ០១២៧៤៣
៤២៤-វរសេនីយ៍ឯក ស្ងួន វិសាល អត្តលេខ ០០៥១៦៧
៤២៥-វរសេនីយ៍ឯក ព្រហ្ម ច័ន្ទឬទ្ធី អត្តលេខ ០១៣៨១៤
៤២៦-វរសេនីយ៍ឯក គង់ ឈឿន អត្តលេខ ០០៥១៧៦
៤២៧-វរសេនីយ៍ឯក គង់ ផល្លី អត្តលេខ ០០២៦៤១
៤២៨-វរសេនីយ៍ឯក សៀង សារួន អត្តលេខ ០០២០១៥
៤២៩-វរសេនីយ៍ឯក ចៅ សារិន អត្តលេខ ០២៣៤៤០
៤៣០-វរសេនីយ៍ឯក វ័ត្ថ ជាត្ថានុរក្ស អត្តលេខ ០២៣៤៥៦
៤៣១-វរសេនីយ៍ឯក ស៊ុំ សម អត្តលេខ ០២០៦២៥

៤៣២-វរសេនីយ៍ឯក **យុទ្ធ សេងហាន** អត្តលេខ ០១២៥២៣
៤៣៣-វរសេនីយ៍ឯក **កែង សុផល** អត្តលេខ ០០៣១៩៣
៤៣៤-វរសេនីយ៍ឯក **ចាន់ ថង** អត្តលេខ ០០១៣៧៨

**ខ-ឋានន្តរស័ក្តិឧត្តមនាវីត្រី :**

១-វរនាវីឯក **គៀន គីម** អត្តលេខ ០១៥១៧៤
២-វរនាវីឯក **ឆាន ណារិទ្ធ** អត្តលេខ ០១០៣០៤
៣-វរនាវីឯក **ព្រហ្ម សុខា** អត្តលេខ ០១០២៦០
៤-វរនាវីឯក **ផាន់ អឿន** អត្តលេខ ០១៥០១១

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្ត ព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

នសរ.១៧០២.២៤៥

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៧*

លេខ: ២៤៧ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ០២ ខែ មីនា ឆ្នាំ២០១៧
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០២១៧/២៤៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលតួនាទីភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំងរបស់ អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តម្លើងឋានន្តរស័ក្តិ ជាកិច្ចបច្ឆាមរណៈ ដល់សព នាយទាហាន ថ្នាក់ឧត្តមសេនីយ៍និងថ្នាក់វរសេនីយ៍ នៃកងយោធពលខេមរភូមិន្ទ ៖

**ក-ឋានន្តរស័ក្តិឧត្តមសេនីយ៍ទោ**

១-ឧត្តមសេនីយ៍ត្រី **យិន សុន្ទរៈ** អត្តលេខ ០០៩៥៦២

២-ឧត្តមសេនីយ៍ត្រី **ឡាច សាមេធ** អត្តលេខ ០០៩០០១

**ខ-ឋានន្តរស័ក្តិឧត្តមសេនីយ៍ត្រី**

-វរសេនីយ៍ឯក **ហ៊ុល ម៉ុនធឿន** អត្តលេខ ០០៥៥៦៦

**មាត្រា២:** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចារល. ១៧០២.២៤៤

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៧*

លេខ: ២៤១ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ២០១៧
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០២១៧/២៤៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៧ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំអង្គការតុលាការ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៦ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បន្ទាប់ពីបានការសម្រេចរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម នាសម័យប្រជុំថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៧

## ត្រាស់បង្គាប់

**មាត្រា១:** ដាក់វិន័យលោក **សាំង សេរី** ចៅក្រមសាលាដំបូងខេត្តកោះកុង ក្រោមរូបភាព ផ្លាស់ដោយបង្ខំចាត់ឲ្យទៅក្រសួងយុត្តិធម៌ អាចតម្រូវឲ្យទទួលការបណ្តុះបណ្តាលបន្ថែម និងការព្យួរពីការងារមិនឲ្យមានបៀវត្ស ក្នុងរយៈពេល០៤(ប្រាំបួន)ខែ។

**មាត្រា២:** ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

[illegible]

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១៧*

លេខ:២៥០ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ .ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ២០១៧
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០២១៧/២៤៦

## យើង

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៧ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៦ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បន្ទាប់ពីបានការសម្រេចរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម នាសម័យប្រជុំថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៧

## ត្រាស់បង្គាប់

**មាត្រា១:** តែងតាំង និងផ្ទេរមុខតំណែង ប្រធាន អនុប្រធាន ចៅក្រម សាលាដំបូងរាជធានី-ខេត្តៈ

### ក- ប្រធានសាលាដំបូងខេត្ត

| | |
|---|---|
| ១-លោក **មីន មករា** | អនុប្រធានសាលាដំបូងខេត្តកោះកុង ត្រូវបានតែងតាំងជាប្រធានសាលាដំបូងខេត្តកោះកុង ជំនួសលោក ហួន ម៉ានី ដែលបានដាក់ឱ្យចូលនិវត្តន៍ |
| ២-លោក **ហាច់ ស៊ីថា** | អនុប្រធានសាលាដំបូងខេត្តពោធិ៍សាត់ ត្រូវបានតែងតាំងជាប្រធានសាលាដំបូងខេត្តកំពង់ស្ពឺ ជំនួសលោក ខ្លូត ពេជ្រ ដែលបានដាក់ឱ្យចូលនិវត្តន៍ |
| ៣-លោក **អ៊ិត សម្ផស្ស** | អនុប្រធានសាលាដំបូងខេត្តបន្ទាយមានជ័យ ត្រូវបានតែងតាំងជាប្រធានសាលាដំបូងខេត្តពោធិ៍សាត់ ជំនួសលោក ថោង អុល ដែលបានដាក់ឱ្យចូលនិវត្តន៍ |

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

៤-លោក **ឡុង គេសតីរម្យ** ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ត្រូវបានតែងតាំងជាប្រធានសាលាដំបូងខេត្តកំពត ជំនួសលោក គាំ ឈាន ដែលបានដាក់ឱ្យចូលនិវត្តន៍

**ខ- អនុប្រធានសាលាដំបូងរាជធានី-ខេត្ត**

១-លោក **គី ឫទ្ធី** អនុប្រធានសាលាដំបូងខេត្តសៀមរាប ត្រូវបានផ្ទេរមុខតំណែងឱ្យមកបម្រើការងារជាអនុប្រធានសាលាដំបូងរាជធានីភ្នំពេញ

២-លោក **ឌុច សុខសារិន** អនុប្រធានសាលាដំបូងខេត្តសៀមរាប ត្រូវបានផ្ទេរមុខតំណែងឱ្យមកបម្រើការងារជាអនុប្រធានសាលាដំបូងរាជធានីភ្នំពេញ

៣-លោកស្រី **គឹម លុយ** អនុប្រធានសាលាដំបូងខេត្តកំពង់ឆ្នាំង ត្រូវបានផ្ទេរមុខតំណែងឱ្យមកបម្រើការងារជាអនុប្រធានសាលាដំបូងខេត្តកំពង់ចាម

៤-លោក **អ៊ុំ ចាន់ថុល** អនុប្រធានសាលាដំបូងខេត្តកំពង់ចាម ត្រូវបានផ្ទេរមុខតំណែងឱ្យមកបម្រើការងារជាអនុប្រធានសាលាដំបូងខេត្តសៀមរាប

៥-លោក **កែម មុនី** អនុប្រធានសាលាដំបូងរាជធានីភ្នំពេញ ត្រូវបានផ្ទេរមុខតំណែងឱ្យមកបម្រើការងារជាអនុប្រធានសាលាដំបូងខេត្តព្រះសីហនុ

៦-លោក **តាត់ គីមសៀ** អនុប្រធានសាលាដំបូងខេត្តព្រៃវែង ត្រូវបានផ្ទេរមុខតំណែងឱ្យមកបម្រើការងារជាអនុប្រធានសាលាដំបូងខេត្តព្រះសីហនុ

៧-លោកស្រី **ជ័យ មាលា** អនុប្រធានសាលាដំបូងខេត្តរតនគិរី ត្រូវបានផ្ទេរមុខតំណែងឱ្យមកបម្រើការងារជាអនុប្រធានសាលាដំបូងខេត្តតាកែវ

៨-លោក **ហម ម៉េងសែ** អនុប្រធានសាលាដំបូងខេត្តស្វាយរៀង ត្រូវបានផ្ទេរមុខតំណែងឱ្យមកបម្រើការងារជាអនុប្រធានសាលាដំបូងខេត្តកំពង់ឆ្នាំង

៩-លោក **យុត ពន្លឺ** អនុប្រធានសាលាដំបូងខេត្តព្រះវិហារ ត្រូវបានផ្ទេរមុខតំណែងឱ្យមកបម្រើការងារជាអនុប្រធានសាលាដំបូងខេត្តកំពង់ធំ

១០-លោក **កែ សាខន** អនុប្រធានសាលាដំបូងខេត្តតាកែវ ត្រូវបានផ្ទេរមុខតំណែងឱ្យមកបម្រើការងារជាអនុប្រធានសាលាដំបូងខេត្តព្រៃវែង

១១-លោកស្រី **ពេជ ម៉ារ៉ែន** ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ត្រូវបានតែងតាំងជាអនុប្រធានសាលាដំបូងខេត្តកណ្ដាល

១២-លោក **កែវ សុខា** ចៅក្រមសាលាដំបូងខេត្តមណ្ឌលគិរី ត្រូវបានតែងតាំងជាអនុប្រធានសាលាដំបូងខេត្តកោះកុង

១៣-លោក **លី ម៉េង** ចៅក្រមសាលាដំបូងខេត្តបន្ទាយមានជ័យ ត្រូវបានតែងតាំងជាអនុប្រធានសាលាដំបូងខេត្តប៉ៃលិន

១៤-លោក **ទ្រី សុផ័ត** ចៅក្រមសាលាដំបូងខេត្តបាត់ដំបង ត្រូវបានតែងតាំងជាអនុប្រធានសាលាដំបូងខេត្តឧត្តរមានជ័យ

១៥-លោក **សែត ទិសិដ្ឋមុនី** ចៅក្រមសាលាដំបូងខេត្តកំពង់ចាម ត្រូវបានតែងតាំងជាអនុប្រធានសាលាដំបូងខេត្តព្រះវិហារ

១៦-លោក **ឈុន ច័ន្ទសីហា** ចៅក្រមសាលាដំបូងខេត្តសៀមរាប ត្រូវបានតែងតាំងជាអនុប្រធានសាលាដំបូងខេត្តរតនគិរី

**គ- ចៅក្រមសាលាដំបូងរាជធានី-ខេត្ត**

១-លោក **កើត សាំង** ចៅក្រមសាលាដំបូងខេត្តស្វាយរៀង ត្រូវបានផ្ទេរមុខតំណែងឱ្យមកបម្រើការងារជាចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

២-លោក **វ៉ាន់ សែនវិសុទ្ធ** ចៅក្រមសាលាដំបូងខេត្តតាកែវ ត្រូវបានផ្ទេរមុខតំណែងឱ្យមកបម្រើការងារជាចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

៣-លោក **ហាន សុខេមរិន** ចៅក្រមសាលាដំបូងខេត្តព្រៃវែង ត្រូវបានផ្ទេរមុខតំណែងឱ្យមកបម្រើការងារជាចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

៤-លោក **អ៊ុក សុវណ្ណារិទ្ធ** ចៅក្រមសាលាដំបូងខេត្តបាត់ដំបង ត្រូវបានផ្ទេរមុខតំណែងឱ្យមកបម្រើការងារជាចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

៥-លោក **ឡុង វណ្ណា** ចៅក្រមសាលាដំបូងខេត្តប៉ៃលិន ត្រូវបានផ្ទេរមុខតំណែងឱ្យមកបម្រើការងារជាចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

៦-លោក **សាយ សារុន** ចៅក្រមសាលាដំបូងខេត្តស្ទឹងត្រែង ត្រូវបានផ្ទេរមុខតំណែងឱ្យមកបម្រើការងារជាចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

៧-លោកស្រី **លី ម៉ារីណា** ចៅក្រមសាលាដំបូងខេត្តប៉ៃលិន ត្រូវបានផ្ទេរមុខតំណែងឱ្យមកបម្រើការងារជាចៅក្រមសាលាដំបូងខេត្តកំពង់ចាម

៨-លោក **សួន សំណាង** ចៅក្រមសាលាដំបូងខេត្តស្វាយរៀង ត្រូវបានផ្ទេរមុខតំណែងឱ្យមកបម្រើការងារជាចៅក្រមសាលាដំបូងខេត្តកំពង់ចាម

៩-លោកស្រី **ហៃ ណៃហេង** ចៅក្រមសាលាដំបូងខេត្តកំពង់ចាម ត្រូវបានផ្ទេរមុខតំណែងឱ្យមកបម្រើការងារជាចៅក្រមសាលាដំបូងខេត្តត្បូងឃ្មុំ

១០-លោក **វ៉ែម សុតត្ថិ** ចៅក្រមសាលាដំបូងខេត្តសៀមរាប ត្រូវបានផ្ទេរមុខតំណែងឱ្យមកបម្រើការងារជាចៅក្រមសាលាដំបូងខេត្តបាត់ដំបង

១១-លោក **រ័ត្ន ស៊ីថា** ចៅក្រមសាលាដំបូងខេត្តប៉ៃលិន ត្រូវបានផ្ទេរមុខតំណែងឱ្យមកបម្រើការងារជាចៅក្រមសាលាដំបូងខេត្តបាត់ដំបង

១២-លោក **ញូច ចន្ធី** ចៅក្រមសាលាដំបូងខេត្តកំពង់ឆ្នាំង ត្រូវបានផ្ទេរមុខតំណែងឱ្យមកបម្រើការងារជាចៅក្រមសាលាដំបូងខេត្តបាត់ដំបង

១៣-លោក **ស៊ិត វណ្ណារ៉ា** ចៅក្រមសាលាដំបូងខេត្តកំពង់ធំ ត្រូវបានផ្ទេរមុខតំណែងឱ្យមកបម្រើការងារជាចៅក្រមសាលាដំបូងខេត្តប៉ៃលិន

១៤-លោក **សុទ្ធ សំអេក** ចៅក្រមសាលាដំបូងខេត្តកំពង់ឆ្នាំង ត្រូវបានផ្ទេរមុខតំណែងឱ្យមកបម្រើការងារជាចៅក្រមសាលាដំបូងខេត្តប៉ៃលិន

១៥-លោក **គួន ចន្ថា** ចៅក្រមសាលាដំបូងខេត្តឧត្តរមានជ័យ ត្រូវបានផ្ទេរមុខតំណែងឱ្យមកបម្រើការងារជាចៅក្រមសាលាដំបូងខេត្តព្រះសីហនុ

១៦-លោក **ឡុញ ច័ន្ទចេតនា** ចៅក្រមសាលាដំបូងខេត្តតាកែវ ត្រូវបានផ្ទេរមុខតំណែងឱ្យមកបម្រើការងារជាចៅក្រមសាលាដំបូងខេត្តព្រះសីហនុ

១៧-លោកស្រី **គីម សុគន្ធា** ចៅក្រមសាលាដំបូងខេត្តក្រចេះ ត្រូវបានផ្ទេរមុខតំណែងឱ្យមកបម្រើ ការងារជាចៅក្រមសាលាដំបូងខេត្តសៀមរាប

១៨-លោក **តែ ថីរៈ** ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ត្រូវបានផ្ទេរមុខតំណែងឱ្យមកបម្រើការងារជាចៅក្រមសាលាដំបូងខេត្តសៀមរាប

១៩-លោក **លី ចន្ថា** ចៅក្រមសាលាដំបូងខេត្តពោធិសាត់ ត្រូវបានផ្ទេរមុខតំណែងឱ្យមកបម្រើការងារជាចៅក្រមសាលាដំបូងខេត្តឧត្តរមានជ័យ

២០-លោក **ញឹម ពិសាល** ចៅក្រមសាលាដំបូងខេត្តព្រះសីហនុ ត្រូវបានផ្ទេរមុខតំណែងឱ្យមកបម្រើការងារជាចៅក្រមសាលាដំបូងខេត្តបន្ទាយមានជ័យ

២១-លោក **ផេង កុសល** ចៅក្រមសាលាដំបូងខេត្តឧត្តរមានជ័យ ត្រូវបានផ្ទេរមុខតំណែងឱ្យមកបម្រើការងារជាចៅក្រមសាលាដំបូងខេត្តបន្ទាយមានជ័យ

២២-លោក **អាំង សុភា** ចៅក្រមសាលាដំបូងខេត្តឧត្តរមានជ័យ ត្រូវបានផ្ទេរមុខតំណែងឱ្យមកបម្រើការងារជាចៅក្រមសាលាដំបូងខេត្តកំពត

២៣-លោកស្រី **លី សុជាណែត** ចៅក្រមសាលាដំបូងខេត្តព្រះសីហនុ ត្រូវបានផ្ទេរមុខតំណែងឱ្យមកបម្រើការងារជាចៅក្រមសាលាដំបូងខេត្តកំពត

២៤-លោក **ពេជ្រ ចិន្តា** ចៅក្រមសាលាដំបូងខេត្តពោធិសាត់ ត្រូវបានផ្ទេរមុខតំណែងឱ្យមកបម្រើការងារជាចៅក្រមសាលាដំបូងខេត្តកំពង់ស្ពឺ

២៥-លោក **នូ ដារ៉ា** ចៅក្រមសាលាដំបូងខេត្តប៉ៃលិន ត្រូវបានផ្ទេរមុខតំណែងឱ្យមកបម្រើការងារជាចៅក្រមសាលាដំបូងខេត្តតាកែវ

២៦-លោកស្រី **ខៀវ ផាន់ណា** ចៅក្រមសាលាដំបូងខេត្តកំពត ត្រូវបានផ្ទេរមុខតំណែង តំណែងឱ្យមកបម្រើការងារជាចៅក្រមសាលាដំបូងខេត្តកំពង់ឆ្នាំង

២៧-លោក **ហេង សុខជា** ចៅក្រមសាលាដំបូងខេត្តព្រៃវែង ត្រូវបានផ្ទេរមុខតំណែងឱ្យមកបម្រើការងារជាចៅក្រមសាលាដំបូងខេត្តកំពង់ធំ

២៨-លោក **យ៉ាន សុភាព** ចៅក្រមសាលាដំបូងខេត្តកំពង់ស្ពឺ ត្រូវបានផ្ទេរមុខតំណែងឱ្យមកបម្រើការងារជាចៅក្រមសាលាដំបូងខេត្តពោធិសាត់

២៩-លោក **សុន នាថធាវី** ចៅក្រមសាលាដំបូងខេត្តប៉ៃលិន ត្រូវបានផ្ទេរមុខតំណែងឱ្យមកបម្រើការងារជាចៅក្រមសាលាដំបូងខេត្តពោធិសាត់

៣០-លោកស្រី **រស់ បូផាណា** ចៅក្រមសាលាដំបូងខេត្តកំពត ត្រូវបានផ្ទេរមុខតំណែងឱ្យមកបម្រើ ការងារជាចៅក្រមសាលាដំបូងខេត្តព្រៃវែង

៣១-លោក **អ៊ិន ម៉ិនលី** ចៅក្រមសាលាដំបូងខេត្តឧត្តរមានជ័យ ត្រូវបានផ្ទេរមុខតំណែងឱ្យមកបម្រើការងារជាចៅក្រមសាលាដំបូងខេត្តព្រៃវែង

៣២-លោក **អេង ចំនាប់** ចៅក្រមសាលាដំបូងខេត្តរតនគិរី ត្រូវបានផ្ទេរមុខតំណែងឱ្យមកបម្រើការងារជាចៅក្រមសាលាដំបូងខេត្តក្រចេះ

៣៣-លោក **សោ ពន្លក** ចៅក្រមសាលាដំបូងខេត្តព្រះវិហារ ត្រូវបានផ្ទេរមុខតំណែងឱ្យមកបម្រើការងារជាចៅក្រមសាលាដំបូងខេត្តស្វាយរៀង

៣៤-លោកស្រី **ឈុន ដាវី** ចៅក្រមសាលាដំបូងខេត្តកោះកុង ត្រូវបានផ្ទេរមុខតំណែងឱ្យមកបម្រើការងារជាចៅក្រមសាលាដំបូងខេត្តស្វាយរៀង

**មាត្រា២:** ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

នស/រកត/០២១៧/២៤៥ **នរោត្តម សីហមុនី**

លេខ: ២៥៤ ស.ណ

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១៧*

**សំណៅចែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ២០១៧

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៣៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការប្រគល់មុខងារគ្រប់គ្រងមណ្ឌលថែទាំកុមាររបស់រដ្ឋទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ការប្រគល់មុខងារត្រួតពិនិត្យមណ្ឌលថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាល ទៅឱ្យរដ្ឋបាលរាជធានី ក្រុង ស្រុក និងការប្រគល់មុខងារគ្រប់គ្រង សេវាថែទាំកុមាររងគ្រោះ និងងាយរងគ្រោះនៅក្នុងសហគមន៍ទៅឱ្យ រដ្ឋបាលរាជធានី រដ្ឋបាលក្រុង និងរដ្ឋបាលឃុំ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/០៩៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យ ប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៧៣ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានី ក្រុមប្រឹក្សា គណៈអភិបាលខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ ៦៨ អនក្រ.បក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១២ ស្តីពីដំណើរការទូទៅនៃការផ្ទេរមុខងារនិងធនធានឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះមានគោលបំណងធ្វើឱ្យប្រសើរឡើងនូវគុណភាពសេវាសុខុមាលភាពដល់កុមារនៅក្នុងព្រះរាជាណាចក្រកម្ពុជាតាមរយៈការបង្វិតការសម្រេចចិត្ត និងការទទួលខុសត្រូវក្នុងការផ្តល់សេវាទាំងនេះទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិដែលនៅកៀកជិតកុមាររងគ្រោះ និងងាយរងគ្រោះ។

**មាត្រា២.-**

អនុក្រឹត្យនេះមានគោលដៅ៖

- ប្រគល់មុខងារគ្រប់គ្រងមណ្ឌលថែទាំកុមាររបស់រដ្ឋទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ប្រគល់មុខងារត្រួតពិនិត្យមណ្ឌលថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាលទៅឱ្យរដ្ឋបាលរាជធានី រដ្ឋបាលក្រុង ស្រុក និងប្រគល់មុខងារគ្រប់គ្រងសេវាថែទាំកុមាររងគ្រោះ និងងាយរងគ្រោះនៅក្នុងសហគមន៍ទៅឱ្យរដ្ឋបាលរាជធានី រដ្ឋបាលក្រុង និងរដ្ឋបាលឃុំ
- ផ្ទេរធនធានហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ និងធនធានមនុស្សទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ សម្រាប់អនុវត្តមុខងារដែលបានប្រគល់
- កំណត់ការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពជំនាញ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីគាំទ្រការអនុវត្តមុខងារដែលបានប្រគល់
- កំណត់គោលការណ៍ និងនីតិវិធីសម្រាប់អនុវត្តមុខងារដែលបានប្រគល់ប្រកបដោយគុណភាព គណនេយ្យភាព ប្រសិទ្ធភាព និងសមធម៌។

**មាត្រា៣.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះមុខងារគ្រប់គ្រងមណ្ឌលថែទាំកុមាររបស់រដ្ឋ មុខងារត្រួតពិនិត្យមណ្ឌលថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាល និងមុខងារគ្រប់គ្រងសេវាថែទាំកុមាររងគ្រោះ និងងាយរងគ្រោះក្នុងសហគមន៍នៅរដ្ឋបាលថ្នាក់ក្រោមជាតិទូទាំងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៤.-**

វាក្យស័ព្ទបច្ចេកទេសប្រើប្រាស់ក្នុងអនុក្រឹត្យនេះមានន័យដូចតទៅ៖

**កុមាររងគ្រោះ និងងាយរងគ្រោះ** គឺជាកុមារដែលស្ថិតក្នុងស្ថានភាពប្រឈមគ្រោះថ្នាក់ដូចជា៖

- កុមារដែលគ្មានឪពុក ម្ដាយ ឬអាណាព្យាបាលនៅជាមួយ
- កុមារបែកចេញពីគ្រួសារ ឬស្ថានភាពគំរាមកំហែងដែលអាចបណ្ដាលឱ្យកុមារបែកចេញពីគ្រួសារតាមរយៈការបោះបង់កុមារចោល ការជាប់ពន្ធនាគារ ការជួញដូរ ឬចំណាកស្រុក
- កុមារទទួលរងការប្រព្រឹត្តអំពើហិង្សា ឬការគំរាម ការបង្កអំពើហិង្សាក្នុងគ្រួសារ ការរំលោភបំពានលើរាងកាយ ឬផ្លូវភេទ ឬការកេងប្រវ័ញ្ចគ្រប់រូបភាពដូចជាការលក់ ឬដូរកុមារជាដើម
- កុមារដែលឪពុកម្ដាយ ឬអាណាព្យាបាលរបស់ខ្លួនពុំមានលទ្ធភាពបំពេញកាតព្វកិច្ចបីបាច់ថែរក្សាដោយសារការខ្វះខាតតម្រូវការចាំបាច់ និងសេវាមូលដ្ឋាន ទីជម្រក ចំណីអាហារ សម្លៀកបំពាក់ ការអប់រំ និងការថែទាំសុខភាព
- កុមារ ឬអ្នកថែទាំកុមារមានជំងឺរ៉ាំរ៉ៃ ឬមានពិការភាពដែលធ្វើឱ្យកុមារមិនអាចទទួលបានការថែទាំសមស្រប

- កុមារដែលគ្រួសារញៀនគ្រឿងស្រវឹង លេងល្បែងស៊ីសង ប្រើប្រាស់សារធាតុញៀនផ្សេងៗដែលមិនអាចផ្តល់ការថែទាំសមស្របដល់កុមារ
- កុមារដែលកំពុងប្រឈម ឬកំពុងមានទំនាស់នឹងច្បាប់ ។

**ការគ្រប់គ្រងមណ្ឌលថែទាំកុមារ** គឺសំដៅដល់ការគ្រប់គ្រង និងការចាត់ចែងឱ្យកុមាររស់នៅជុំគ្នាជាក្រុមក្នុងមណ្ឌលក្រោមការថែទាំរបស់បុគ្គលិកមណ្ឌលសម្រាប់ថែទាំកុមារ ដើម្បីផ្តល់អាហារ សម្លៀកបំពាក់ ថែទាំសុខភាព ការអប់រំ វិន័យ សីលធម៌ ការអភិវឌ្ឍក្នុងសង្គម និងដោះស្រាយបញ្ហាផ្សេងទៀតរបស់កុមារ។

**ការត្រួតពិនិត្យមណ្ឌលថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាល** គឺសំដៅដល់ការធ្វើអធិការកិច្ចលើការផ្តល់សេវាថែទាំកុមារនៅក្នុងមណ្ឌលរបស់អង្គការមិនមែនរដ្ឋាភិបាល ផ្ទៀងផ្ទាត់ទៅនឹងបទដ្ឋានអប្បបរមាដែលបានកំណត់សម្រាប់ការថែទាំកុមារក្នុងមណ្ឌល។

**ការគ្រប់គ្រងសេវាថែទាំកុមាររងគ្រោះ និងងាយរងគ្រោះក្នុងសហគមន៍** គឺសំដៅដល់ការជួយអន្តរាគមន៍ និងដោះស្រាយដល់កុមាររងគ្រោះ និងងាយរងគ្រោះនៅក្នុងសហគមន៍ ដោយចាត់ចែង និងសម្របសម្រួលផ្តល់នូវអាហារ សម្លៀកបំពាក់ ជម្រកសុវត្ថិភាព ការថែទាំសុខភាព ការអប់រំ វិន័យ សីលធម៌ ការអភិវឌ្ឍក្នុងសង្គម និងដោះស្រាយបញ្ហាផ្សេងៗទៀតរបស់កុមារ ដោយអនុវត្តតាមបទដ្ឋានអប្បបរមាសម្រាប់ការថែទាំជំនួសចំពោះកុមារនៅតាមសហគមន៍។

**មណ្ឌលថែទាំកុមារ** គឺសំដៅដល់មណ្ឌលរបស់រដ្ឋ ឬរបស់អង្គការមិនមែនរដ្ឋាភិបាល ដែលទទួលស្គាល់ដោយក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច សម្រាប់ចិញ្ចឹមថែទាំ និងផ្តល់នូវតម្រូវការជាមូលដ្ឋានសម្រាប់ការអភិវឌ្ឍរបស់កុមារដែលគ្មានឪពុកម្តាយ ឬគ្មានឪពុក ឬគ្មានម្តាយ ឬកុមារដែលត្រូវគេបោះបង់ចោល ឬកុមារដែលឪពុកម្តាយ ឬអ្នកអាណាព្យាបាលពុំមានលទ្ធភាពផ្តល់ការថែទាំឱ្យបានគ្រប់គ្រាន់ និងជាជម្រើសចុងក្រោយសម្រាប់ការថែទាំជំនួសចំពោះកុមាររងគ្រោះ និងងាយរងគ្រោះ។

**ការថែទាំជំនួស** គឺសំដៅដល់ការថែទាំដែលផ្តល់ទៅឱ្យកុមារដែលមិនស្ថិតនៅក្រោមការថែទាំរបស់ឪពុកម្តាយបង្កើតរបស់ខ្លួន។ រាល់ករណីទុកដាក់កុមារតាមការថែទាំជំនួសទាំងអស់គឺជា "ការថែទាំបណ្តោះអាសន្ន" លើកលែងតែការទុកដាក់ជាអចិន្ត្រៃយ៍ក្នុងគ្រួសារ។

**ផែនការអចិន្ត្រៃយ៍** គឺសំដៅដល់កិច្ចខិតខំប្រឹងប្រែងរកគ្រួសារមួយឱ្យកុមារ ដើម្បីរស់នៅជាមួយជាអចិន្ត្រៃយ៍ តាមរយៈការទុកដាក់ជាមួយសាច់ញាតិ អាណាព្យាបាលក្នុងប្រទេស សុំកូនក្នុងប្រទេស និងសុំកូនអន្តរប្រទេស។

**ការបិទករណីកុមារ** គឺសំដៅដល់ការវិលត្រលប់របស់កុមារទៅរស់នៅជួបជុំជាមួយឪពុក ម្តាយ ឬអាណាព្យាបាលវិញ ហើយសេវាគាំទ្រគ្រួសារមានបន្តក្នុងរយៈពេលកំណត់ណាមួយ អ្នកកាន់ករណីពាក់ព័ន្ធអាចបិទករណីទៅតាមស្ថានភាពជាក់ស្តែងនៃករណីនីមួយៗ និងលទ្ធភាពនៃប្រភពធនធានដែលអាចរកបាន។

# ជំពូកទី២
# ការប្រគល់មុខងារគ្រប់គ្រងមណ្ឌលថែទាំកុមាររបស់រដ្ឋទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ការប្រគល់មុខងារត្រួតពិនិត្យមណ្ឌលថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាលទៅឱ្យរដ្ឋបាលរាជធានី ក្រុង ស្រុក និងការប្រគល់មុខងារគ្រប់គ្រងសេវាថែទាំកុមាររងគ្រោះ និងងាយរងគ្រោះនៅក្នុងសហគមន៍ទៅឱ្យរដ្ឋបាលរាជធានី រដ្ឋបាលក្រុង និងរដ្ឋបាលឃុំ

**មាត្រា៥.-**

ប្រគល់មុខងារ "ការគ្រប់គ្រងមណ្ឌលថែទាំកុមាររបស់រដ្ឋ" ទៅឱ្យរដ្ឋបាលរាជធានី ខេត្តទូទាំងប្រទេស។

កិច្ចការនានាពាក់ព័ន្ធនឹងមុខងារ "ការគ្រប់គ្រងមណ្ឌលថែទាំកុមាររបស់រដ្ឋ"ដែលត្រូវបានប្រគល់ទៅឱ្យរដ្ឋបាលរាជធានី ខេត្ត រួមមាន៖

- ការពិនិត្យ និងសម្រេចលើសំណុំឯកសារដែលសុំបញ្ចូល ឬបញ្ចេញកុមាររងគ្រោះ និងងាយរងគ្រោះនៅក្នុងមណ្ឌលថែទាំកុមាររបស់រដ្ឋ
- ការគ្រប់គ្រង ផ្តល់អាហារ សម្លៀកបំពាក់ ថែទាំសុខភាព ការអប់រំ វិន័យ សីលធម៌ ការអភិវឌ្ឍក្នុងសង្គមដល់កុមារនៅក្នុងមណ្ឌល និងដោះស្រាយបញ្ហាផ្សេងៗទៀតរបស់កុមារទាំងនោះ
- ការគ្រប់គ្រងករណីកុមារនៅក្នុងមណ្ឌល ការធ្វើសមាហរណកម្ម ការបង្រួបបង្រួមគ្រួសារ ការតាមដាន និងការបិទករណីរបស់កុមារ
- ការរៀបចំផែនការអចិន្ត្រៃយ៍សម្រាប់កុមារនៅក្នុងមណ្ឌលរដ្ឋ ដើម្បីរកគ្រួសារកុមារ
- ការផ្សព្វផ្សាយការយល់ដឹងអំពីគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការថែទាំជំនួសចំពោះកុមារដល់មន្ត្រី បុគ្គលិកក្រោមឱវាទ និងប្រជាជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ការបណ្តុះបណ្តាលបំណិនជីវិត និងជំនាញវិជ្ជាជីវៈនានាសម្រាប់កុមារអាយុច្រើនដែលមិនអាចរកគ្រួសារអចិន្ត្រៃយ៍បានមុនពេលពួកគេឈានដល់ភាពពេញវ័យ
- ការរៀបចំបញ្ជីបច្ចុប្បន្នភាពកុមារនៅក្នុងមណ្ឌលរដ្ឋ និងសំណុំឯកសារដែលត្រូវស្នើសុំកូនធ្វើមកក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

**មាត្រា៦.-**

ប្រគល់មុខងារ "ការត្រួតពិនិត្យមណ្ឌលថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាល" ទៅឱ្យរដ្ឋបាលរាជធានី ក្រុង ស្រុក។

កិច្ចការនានាពាក់ព័ន្ធនឹងមុខងារត្រួតពិនិត្យមណ្ឌលថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាល ដែលត្រូវបានប្រគល់ទៅឱ្យរដ្ឋបាលរាជធានី ក្រុង ស្រុក រួមមាន៖

- ការធ្វើអធិការកិច្ចលើការអនុវត្តតាមបទដ្ឋានអប្បបរមា សម្រាប់ការថែទាំជំនួសចំពោះកុមារនៅក្នុងមណ្ឌលថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាល

- ការសម្របសម្រួលដោះស្រាយករណីរំលោភបំពានលើសិទ្ធិកុមារដែលកើតមាននៅក្នុងមណ្ឌលថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាល
- គ្រប់គ្រង និងវិភាគទិន្នន័យកុមាររងគ្រោះ និងងាយរងគ្រោះ និងកុមារដែលកំពុងស្ថិតនៅក្នុងការថែទាំជំនួសក្នុងសហគមន៍
- ការរៀបចំបញ្ជីបច្ចុប្បន្នភាព នៃអង្គការមិនមែនរដ្ឋាភិបាលដែលត្រូវបានអនុញ្ញាតផ្តល់ការថែទាំជំនួសចំពោះកុមារ
- ការជំរុញលើកទឹកចិត្តឱ្យអង្គការមិនមែនរដ្ឋាភិបាលផ្តល់សេវាថែទាំកុមាររងគ្រោះ និងងាយរងគ្រោះ
- ការពិនិត្យ និងសម្រេចលើសំណុំឯកសារដែលសុំបញ្ចូល ឬបញ្ចេញកុមាររងគ្រោះ និងងាយរងគ្រោះសម្រាប់មណ្ឌលថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាល
- ការតាមដានការបញ្ជូនករណីកុមារ និងការផ្តល់សេវាសុខុមាលភាពកុមារនៅក្នុងមណ្ឌលថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាល។

រដ្ឋបាលរាជធានីត្រូវប្រតិភូកម្មមុខងារ "ការត្រួតពិនិត្យមណ្ឌលថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាល" ទៅឱ្យរដ្ឋបាលខណ្ឌ។

**មាត្រា៧**.-

ប្រគល់មុខងារ "ការគ្រប់គ្រងសេវាថែទាំកុមាររងគ្រោះ និងងាយរងគ្រោះនៅក្នុងសហគមន៍" ទៅឱ្យរដ្ឋបាលរាជធានី រដ្ឋបាលក្រុង និងរដ្ឋបាលឃុំ។

កិច្ចការនានាពាក់ព័ន្ធនឹងមុខងារគ្រប់គ្រងសេវាថែទាំកុមាររងគ្រោះ និងងាយរងគ្រោះនៅក្នុងសហគមន៍ដែលត្រូវបានប្រគល់ទៅឱ្យរដ្ឋបាលរាជធានី រដ្ឋបាលក្រុង និងរដ្ឋបាលឃុំ រួមមាន៖

- ការប្រមូលទិន្នន័យកុមាររងគ្រោះ និងងាយរងគ្រោះ និងកុមារដែលកំពុងស្ថិតនៅក្នុងការថែទាំជំនួសក្នុងសហគមន៍
- ការប្រមូលទិន្នន័យអង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ និងអ្នកពាក់ព័ន្ធ ដើម្បីធ្វើផែនទីសេវាសង្គម
- ការវាយតម្លៃអំពីភាពខ្លាំង ភាពខ្សោយ និងតម្រូវការរបស់កុមារដែលស្ថិតក្នុងស្ថានភាពប្រឈមគ្រោះថ្នាក់ក្នុងគ្រួសារ
- ការរៀបចំផែនការសេវាគ្រួសារ និងស្វែងរកសេវាចាំបាច់នានា ដើម្បីរក្សាកុមារដែលស្ថិតក្នុងស្ថានភាពប្រឈមគ្រោះថ្នាក់ក្នុងគ្រួសារឱ្យរស់ជុំគ្រួសារ និងតាមដានដំណើរការវិវឌ្ឍរបស់កុមារទាំងនោះ
- ការសម្រេចបិទករណី ឬទុកដាក់កុមារដែលស្ថិតក្នុងស្ថានភាពប្រឈមគ្រោះថ្នាក់ក្នុងគ្រួសារជាបណ្តោះអាសន្នតាមការថែទាំជំនួស

- ការរៀបចំទុកដាក់ជាបណ្ដោះអាសន្ននៅកន្លែងមានសុវត្ថិភាពចំពោះកុមារដែលត្រូវបានគេបោះបង់ចោលតាមរយៈការថែទាំជាមួយសាច់ញាតិកុមារ ជាមួយគ្រួសារធម៌ ជាមួយព្រះសង្ឃ កន្លែងសាសនា ការថែទាំជាក្រុមក្នុងសហគមន៍ ឬមណ្ឌលថែទាំកុមារ។

រដ្ឋបាលរាជធានី រដ្ឋបាលក្រុង ត្រូវប្រតិភូកម្មមុខងារ "ការគ្រប់គ្រងសេវាថែទាំកុមាររងគ្រោះ និងងាយរងគ្រោះនៅក្នុងសហគមន៍" ទៅឱ្យរដ្ឋបាលសង្កាត់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

## ជំពូកទី៣
## ការផ្ទេរធនធានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ

**មាត្រា៨.-**

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិត្រូវសម្របសម្រួល ជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក និងឃុំ ដើម្បីកំណត់អំពីកញ្ចប់ធនធានហិរញ្ញវត្ថុ រូបមន្ត លក្ខណវិនិច្ឆ័យ ការបែងចែកធនធាន កាលវិភាគនៃការផ្ទេរ និងលក្ខខណ្ឌនៃការប្រើប្រាស់ធនធានហិរញ្ញវត្ថុសម្រាប់អនុវត្តមុខងារដែលបានប្រគល់។

ការកំណត់កញ្ចប់ធនធានហិរញ្ញវត្ថុ រូបមន្ត លក្ខណវិនិច្ឆ័យ ការបែងចែកធនធាន កាលវិភាគនៃការផ្ទេរ និងលក្ខខណ្ឌនៃការប្រើប្រាស់ធនធានហិរញ្ញវត្ថុទាំងនោះត្រូវកំណត់ដោយប្រកាសអន្តរក្រសួង រវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា៩.-**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវគ្រោងថវិកាចំណាយ សម្រាប់អនុវត្តមុខងារនានា ដែលបានផ្ទេរឱ្យទៅដល់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក និងឃុំ នៅក្នុងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវជូនដំណឹងជាផ្លូវការទៅរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក និងឃុំ អំពីទំហំធនធានហិរញ្ញវត្ថុដែលត្រូវផ្ទេរសម្រាប់អនុវត្តមុខងារដែលបានផ្ទេរទាំងនោះ ដើម្បីបញ្ចូលទៅក្នុងគម្រោងថវិកាប្រចាំឆ្នាំ។

**មាត្រា១០.-**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវផ្ទេរថវិកា និងរៀបចំគោលការណ៍ណែនាំស្ដីពីនីតិវិធីអនុវត្តថវិកាសម្រាប់អនុវត្តមុខងារការគ្រប់គ្រងមណ្ឌលថែទាំកុមាររបស់រដ្ឋ មុខងារត្រួតពិនិត្យមណ្ឌលថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាល និងមុខងារគ្រប់គ្រងសេវាថែទាំកុមាររងគ្រោះនិងងាយរងគ្រោះ នៅក្នុងសហគមន៍ទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក និងឃុំ ទៅតាមនីតិវិធីដែលកំណត់ដោយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា១១.-**

រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់អាចប្រើប្រាស់ចំណែកធនធានគ្មានភ្ជាប់លក្ខខណ្ឌ និងធនធានដែលកៀរគរបានពីប្រភពស្របច្បាប់ផ្សេងទៀត សម្រាប់គាំទ្រដល់ការអនុវត្តមុខងារដែលបានប្រគល់។

**មាត្រា១២.-**

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិត្រូវសម្របសម្រួលជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីកំណត់អំពីទ្រព្យសម្បត្តិដែលត្រូវផ្ទេរឱ្យទៅដល់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក និងឃុំ សម្រាប់គាំទ្រការអនុវត្តមុខងារដែលបានប្រគល់។

**មាត្រា១៣.-**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវសហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីរៀបចំផ្ទេរទ្រព្យសម្បត្តិនានាដែលកំពុងប្រើប្រាស់សម្រាប់អនុវត្តមុខងារដូចមានចែងក្នុងមាត្រា ១២ នៃអនុក្រឹត្យនេះឱ្យទៅដល់រដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក និងឃុំ សម្រាប់គ្រប់គ្រង ចាត់ចែង និងប្រើប្រាស់។

ការផ្ទេរទ្រព្យសម្បត្តិខាងលើនេះ ត្រូវធ្វើឡើងដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយមានការពិគ្រោះយោបល់ជាមួយរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា១៤.-**

រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក និងឃុំ ត្រូវគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ធនធានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិដែលបានផ្ទេរឱ្យសម្រាប់អនុវត្តមុខងារស្របតាមលក្ខខណ្ឌ និងនីតិវិធីនានាដែលបានកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ជំពូកទី៤
## ការផ្ទេរធនធានមនុស្ស

**មាត្រា១៥.-**

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ត្រូវសម្របសម្រួលជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងមុខងារសាធារណៈ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីកំណត់អំពីប្រភេទ និងចំនួនបុគ្គលិកនៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដែលកំពុងគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារដែលបានប្រគល់។

**មាត្រា១៦.-**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវសហការជាមួយក្រសួងមុខងារសាធារណៈ ដើម្បីរៀបចំផ្ទេរបុគ្គលិកដែលបានកំណត់ដូចមានចែងក្នុងមាត្រា១៥ នៃអនុក្រឹត្យនេះឱ្យទៅដល់រដ្ឋបាល រាជធានី ខេត្ត និងរដ្ឋបាលក្រុង ស្រុក តាមនីតិវិធីដែលបានកំណត់ដោយព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។

បុគ្គលិកដែលបានផ្ទេរទៅឱ្យរដ្ឋបាល រាជធានី ខេត្ត និងរដ្ឋបាលក្រុង ស្រុក ត្រូវមានលក្ខខណ្ឌការងារ ប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗមិនទាបជាងលក្ខខណ្ឌការងារ ប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗ ដែលបុគ្គលិកទាំងនោះធ្លាប់បានទទួល។

**មាត្រា១៧.-**

ការគ្រប់គ្រង ការចាត់ចែងបុគ្គលិកដែលបានផ្ទេរឱ្យទៅដល់រដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលក្រុង ស្រុក ត្រូវអនុលោមតាមព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។

## ជំពូកទី៥
## រចនាសម្ព័ន្ធ តួនាទី ភារកិច្ចរបស់រដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក និងឃុំ

**មាត្រា១៨.-**

ផ្ទេរមណ្ឌលថែទាំកុមាររបស់រដ្ឋឱ្យមកស្ថិតក្រោមរចនាសម្ព័ន្ធនៃរដ្ឋបាលរាជធានី ខេត្ត។

**មាត្រា១៩.-**

រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក និងឃុំ ត្រូវទទួលខុសត្រូវលើការគ្រប់គ្រង ការចាត់ចែង និងការ អនុវត្តមុខងារដែលបានប្រគល់ដូចមានចែងក្នុងមាត្រា ៥ មាត្រា ៦ និងមាត្រា៧នៃអនុក្រឹត្យនេះឱ្យមាន ប្រសិទ្ធភាពស្របតាមគោលនយោបាយ និងស្តង់ដារសេវាដែលបានកំណត់។

**មាត្រា២០.-**

ក្នុងការអនុវត្តមុខងារ "ការគ្រប់គ្រងមណ្ឌលថែទាំកុមាររបស់រដ្ឋ" ដូចបានកំណត់ក្នុងមាត្រា៥ នៃ អនុក្រឹត្យនេះ រដ្ឋបាល រាជធានី ខេត្ត ត្រូវ៖

- រៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំសម្រាប់អនុវត្តមុខងារដែលបានប្រគល់
- គ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ធនធានហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ និងបុគ្គលិកដែលបានផ្ទេរសម្រាប់ អនុវត្តមុខងារនានាឱ្យមានប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពស្របតាមគោលការណ៍ បែបបទ និងនីតិវិធីដែលបានកំណត់
- លើកសំណើអំពីតម្រូវការបុគ្គលិកសង្គមកិច្ច និងតម្រូវការនៃការបណ្តុះបណ្តាលជំនាញ
- សហការជាមួយស្ថាប័នពាក់ព័ន្ធ អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធនានា ដើម្បីគាំទ្រដល់ការ អនុវត្តមុខងារ

- កៀរគរការគាំទ្រថវិកា សម្ភារ និងបច្ចេកទេសពីអ្នកពាក់ព័ន្ធនានា និងអាចប្រើប្រាស់ធនធានទាំងនោះតាមឆន្ទានុសិទ្ធិរបស់រដ្ឋបាលរាជធានី ខេត្ត ដើម្បីបង្កើនប្រសិទ្ធភាពនៃការអនុវត្តមុខងារ
- រៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តមុខងារជូនក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- រៀបចំរបាយការណ៍ស្តីពីស្ថានភាពហិរញ្ញវត្ថុនៃការអនុវត្តមុខងារជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា២១.-**

ក្នុងការអនុវត្តមុខងារ "ការត្រួតពិនិត្យមណ្ឌលថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាល" ដូចបានកំណត់ក្នុងមាត្រា ៦ នៃអនុក្រឹត្យនេះ រដ្ឋបាលរាជធានី ក្រុង ស្រុក ត្រូវ៖

- រៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំសម្រាប់អនុវត្តមុខងារដែលបានប្រគល់
- គ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ធនធានហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ និងបុគ្គលិកដែលបានផ្ទេរសម្រាប់អនុវត្តមុខងារនានាឱ្យមានប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពស្របតាមគោលការណ៍ បែបបទ និងនីតិវិធីដែលបានកំណត់
- លើកសំណើអំពីតម្រូវការបុគ្គលិកសង្គមកិច្ច និងតម្រូវការនៃការបណ្តុះបណ្តាលជំនាញ
- សហការជាមួយស្ថាប័នពាក់ព័ន្ធ អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធនានា ដើម្បីគាំទ្រដល់ការអនុវត្តមុខងារ
- កៀរគរការគាំទ្រថវិកា សម្ភារ និងបច្ចេកទេសពីអ្នកពាក់ព័ន្ធនានា និងអាចប្រើប្រាស់ធនធានទាំងនោះ តាមឆន្ទានុសិទ្ធិរបស់រដ្ឋបាល រាជធានី ក្រុង ស្រុក ដើម្បីបង្កើនប្រសិទ្ធភាពនៃការអនុវត្តមុខងារ
- រៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តមុខងារជូនក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- រៀបចំរបាយការណ៍ស្តីពីស្ថានភាពហិរញ្ញវត្ថុនៃការអនុវត្តមុខងារជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា២២.-**

ក្នុងការអនុវត្តមុខងារ "កាគ្រប់គ្រងសេវាថែទាំកុមាររងគ្រោះ និងងាយរងគ្រោះនៅក្នុងសហគមន៍" ដូចបានកំណត់ក្នុងមាត្រា៧នៃអនុក្រឹត្យនេះ រដ្ឋបាលរាជធានី ក្រុង និងរដ្ឋបាលឃុំ ត្រូវ៖

- រៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំសម្រាប់អនុវត្តមុខងារដែលបានប្រគល់
- គ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ធនធានហិរញ្ញវត្ថុដែលបានផ្ទេរសម្រាប់អនុវត្តមុខងារនានាឱ្យមានប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពស្របតាមគោលការណ៍ បែបបទ និងនីតិវិធីដែលបានកំណត់
- លើកសំណើអំពីតម្រូវការបុគ្គលិកសង្គមកិច្ច និងតម្រូវការនៃការបណ្តុះបណ្តាលជំនាញ
- សហការជាមួយស្ថាប័នពាក់ព័ន្ធ អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធនានា ដើម្បីគាំទ្រដល់ការអនុវត្តមុខងារ

- កៀរគរការគាំទ្រថវិកា សម្ភារ និងបច្ចេកទេសពីអ្នកពាក់ព័ន្ធនានា និងអាចប្រើប្រាស់ធនធានទាំងនោះតាមឆន្ទានុសិទ្ធិរបស់រដ្ឋបាលរាជធានី ក្រុង និងឃុំ ដើម្បីបង្កើនប្រសិទ្ធភាពនៃការអនុវត្តមុខងារ
- រៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តមុខងារជូនក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- រៀបចំរបាយការណ៍ស្តីពីស្ថានភាពហិរញ្ញវត្ថុនៃការអនុវត្តមុខងារជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ជំពូកទី៦
## ការគាំទ្រ និងការតាមដាន ត្រួតពិនិត្យនិងវាយតម្លៃ

**មាត្រា២៣.-**

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិត្រូវសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាដល់ការប្រគល់មុខងារ និងធនធានក្នុងការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារទាំងនេះប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពស្របតាមគោលនយោបាយ ស្តង់ដារសេវា គោលការណ៍ និងនីតិវិធីដែលបានកំណត់។

**មាត្រា២៤.-**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាមានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- រៀបចំគោលនយោបាយ ស្តង់ដារសេវា និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងមុខងារដែលបានប្រគល់
- រៀបចំសៀវភៅណែនាំស្តីពីនីតិវិធីអនុវត្តមុខងារ "ការគ្រប់គ្រងមណ្ឌលថែទាំកុមាររបស់រដ្ឋ" "ការត្រួតពិនិត្យមណ្ឌលថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាល" និង"ការគ្រប់គ្រងសេវាថែទាំកុមាររងគ្រោះ និងងាយរងគ្រោះនៅក្នុងសហគមន៍"
- ត្រួតពិនិត្យ និងវាយតម្លៃគុណភាពសេវាដែលបានផ្តល់ដោយរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ក្នុងការអនុវត្តមុខងារ
- ផ្តល់ការបណ្តុះបណ្តាល និងគាំទ្របច្ចេកទេសដល់រដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់អំពីការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារ
- កៀរគរធនធានពីប្រភពនានាសម្រាប់គាំទ្រដល់កម្មវិធី ឬសកម្មភាពនានាពាក់ព័ន្ធនឹងមុខងារដែលបានប្រគល់ឱ្យទៅដល់រដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តមុខងារដែលបានប្រគល់ឱ្យទៅដល់រដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អាចធ្វើប្រតិភូកម្មជូនមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្តក្នុងការគាំទ្រការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃលើការអនុវត្តមុខងារដែលបានប្រគល់។

**មាត្រា២៥.-**

ក្រសួងមហាផ្ទៃមានតួនាទីសម្របសម្រួល និងគាំទ្រដល់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក និងឃុំ ក្នុងការគ្រប់គ្រង ការចាត់ចែង ការអនុវត្តមុខងារ និងធនធាន ដែលបានប្រគល់។

**មាត្រា២៦.-**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានតួនាទីគាំទ្រ និងតាមដានត្រួតពិនិត្យលើការចាត់ចែង និងការប្រើប្រាស់ធនធានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិដែលបានផ្ទេរទៅឱ្យរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក និងឃុំសង្កាត់។

**មាត្រា២៧.-**

ក្រសួងមុខងារសាធារណៈមានតួនាទីគាំទ្រដល់ការផ្ទេរបុគ្គលិកគ្រប់គ្រងមណ្ឌលកុមាររបស់រដ្ឋ និងតាមដាន ត្រួតពិនិត្យការចាត់ចែងបុគ្គលិកដែលបានផ្ទេរឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។

## ជំពូកទី៧
## អន្តរប្បញ្ញត្តិ

**មាត្រា២៨.-**

ក្នុងអំឡុងពេលដែលលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការផ្ទេរឥណទានថវិកាមិនទាន់រៀបចំរួចរាល់ ការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ធនធានហិរញ្ញវត្ថុសម្រាប់អនុវត្តមុខងារត្រូវអនុវត្តតាមបែបបទ និងនីតិវិធីហិរញ្ញវត្ថុដែលកំពុងអនុវត្តបច្ចុប្បន្នដោយត្រូវរាយការណ៍ជូនរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។

## ជំពូកទី៨
## អវសានប្បញ្ញត្តិ

**មាត្រា២៩.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា៣០.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួង

សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និង ប្រធានគ្រប់ស្ថាប័នត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**

នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

សូមមេត្តាចុះហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

**វង សូត**

**កន្លែងទទួល៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣០*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**៣✽៥**

**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

លេខ ៤១៣ ស.អ.យ.

រាជធានីភ្នំពេញ,ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ២០១៧

**សូមគោរពជូន**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**
***ជាទីគោរពដ៏ខ្ពង់ខ្ពស់!***

**កម្មវត្ថុ៖** សំណើសុំពិនិត្យ និងសម្រេចលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការប្រគល់មុខងារពាក់ព័ន្ធនឹងការគ្រប់គ្រងមណ្ឌលថែទាំកុមារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។

**យោង ៖**- អនុក្រឹត្យលេខ ៦៨ អនក្រ.បក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១២ ស្តីពីដំណើរការទូទៅនៃការផ្ទេរមុខងារ និងធនធានឲ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ។
- ផែនការអនុវត្ត៣ឆ្នាំដំណាក់កាលទី២ឆ្នាំ២០១៥-២០១៧ នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទមានកិត្តិយសសូមគោរពជម្រាបជូន **សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** មេត្តាជ្រាបថា ផ្អែកតាមផែនការអនុវត្ត ៣ឆ្នាំ ដំណាក់កាលទី២ (២០១៥-២០១៧) នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងអនុក្រឹត្យលេខ ៦៨ អនក្រ.បក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១២ ស្តីពីដំណើរការទូទៅនៃការផ្ទេរមុខងារ និងធនធានឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រោមការសម្របសម្រួល និងគាំទ្រពីគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) បានរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការប្រគល់មុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងមណ្ឌលថែទាំកុមារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដូចខាងក្រោម៖

១. ការប្រគល់មុខងារគ្រប់គ្រងមណ្ឌលថែទាំកុមាររបស់រដ្ឋទៅឱ្យរដ្ឋបាលរាជធានី ខេត្ត
២.ការប្រគល់មុខងារត្រួតពិនិត្យមណ្ឌលថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាលទៅឱ្យរដ្ឋបាលរាជធានី ក្រុង ស្រុក និង
៣.ការប្រគល់មុខងារគ្រប់គ្រងសេវាថែទាំកុមាររងគ្រោះ និងងាយរងគ្រោះនៅក្នុងសហគមន៍ ទៅឱ្យរដ្ឋបាលរាជធានី រដ្ឋបាលក្រុង និងរដ្ឋបាលឃុំ។

ការរៀបចំ និងដាក់ចេញនូវអនុក្រឹត្យនេះមានគោលបំណងធ្វើឱ្យមានភាពប្រសើរឡើងនូវគុណភាព នៃសេវាសុខុមាលភាពរបស់កុមារ តាមរយៈការបង្វិតការធ្វើសេចក្តីសម្រេចចិត្ត និងការទទួលខុសត្រូវក្នុងការផ្តល់សេវាថែទាំកុមារទាំងនេះទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិដែលនៅកៀកជិតក្រុមកុមាររងគ្រោះ និងងាយរងគ្រោះទាំងនោះ។

សេចក្តីព្រាងអនុក្រឹត្យនេះ ត្រូវបានរៀបចំឡើងដោយផ្អែកលើមេរៀន និងបទពិសោធន៍នៃការធ្វើប្រតិកូកម្មមុខងារគ្រប់គ្រងមណ្ឌលថែទាំងកុមារទាំងនេះទៅឱ្យរដ្ឋបាលខេត្តបាត់ដំបង និងរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ទាំងអស់ក្នុងខេត្តបាត់ដំបង ដែលបានអនុវត្តនៅក្នុងឆ្នាំ២០១៦ កន្លងមក។ ក្រៅពីនេះ សេចក្តីព្រាងអនុក្រឹត្យនេះក៏



ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ. ទូរស័ព្ទ/ទូរសារ : (៨៥៥) ២៣ ៧២៦០៨៦
Ministry of Social Affairs, Veterans and Youth Rehabilitation, #788, Monivong Blvd., Phnom Penh, Cambodia. Fax/Phone: (855) 23 726 086

ត្រូវបានដាក់ឱ្យមានការពិគ្រោះពិភាក្សាជាមួយក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធនានាជាច្រើនលើកច្រើនសារផងដែរ។

ការប្រគល់មុខងារទាំងនេះទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិទូទាំងប្រទេស នឹងត្រូវចាប់ផ្តើមអនុវត្តពីឆ្នាំ២០១៧តទៅ ដោយផ្អែកលើមេរៀន និងបទពិសោធន៍ដែលបានអនុវត្តសាកល្បងនៅក្នុងខេត្តបាត់ដំបង នាពេលកន្លងមក។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើសូម **សម្តេចតេជោនាយករដ្ឋមន្ត្រី** មេត្តាពិនិត្យ និងផ្តល់សេចក្តីសម្រេចដ៏ខ្ពង់ខ្ពស់ ដោយអនុគ្រោះ។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ។

**រដ្ឋមន្ត្រី**

**វង សូត**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ៧៧០ អនក្រ.តត**

**អនុក្រឹត្យ**

**ស្តីពី**

**ការតែងតាំងមន្ត្រីរាជការ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងព័ត៌មាន
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៣៤៩៣ ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១៤ ស្តីពីការគ្រប់គ្រង និងការបើកផ្តល់ប្រាក់បំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងព័ត៌មាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងព័ត៌មាន

**សម្រេច**

**មាត្រា១** : តែងតាំងលោកស្រី **ឈឹម វិសុទ្ធធារី** ជាទីប្រឹក្សាក្រសួងព័ត៌មាន មានឋានៈស្មើ អគ្គនាយករង ។

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងព័ត៌មាន រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល</u> :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ៤៤១ អនក្រ.បក

# អនុក្រឹត្យ
## ស្ដីពី
## ការតែងតាំងក្រុមប្រឹក្សាភិបាលទូរគមនាគមន៍កម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញព្រះរាជក្រមលេខ ០២/នស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៣៩ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៧ ស្ដីពីការអនុវត្តព្រះរាជក្រម ស្ដីពីលក្ខន្តិកៈទូទៅ នៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០៥ ស្ដីពីការបង្កើតទូរគមនាគមន៍កម្ពុជាជាសហគ្រាសសាធារណៈមានលក្ខណៈជាក្រុមហ៊ុនរដ្ឋ
- បានឃើញអនុក្រឹត្យលេខ ២៨ អនក្រ.បក ចុះថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១៦ ស្ដីពីការកែសម្រួលមាត្រា៦ មាត្រា៩ និងមាត្រា១០ នៃអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០៥ ស្ដីពីការបង្កើតទូរគមនាគមន៍កម្ពុជាជាសហគ្រាសសាធារណៈមានលក្ខណៈជាក្រុមហ៊ុនរដ្ឋ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

## សម្រេច

**មាត្រា ១._**

តែងតាំងក្រុមប្រឹក្សាភិបាលទូរគមនាគមន៍កម្ពុជា សម្រាប់អាណត្តិទី៥ ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១ -ឯកឧត្តម **ខុច មករា** | តំណាងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | ប្រធាន |
| ២ -ឯកឧត្តម **គីមរ័ត្ន វិសិដ្ឋ** | តំណាងទីស្ដីការគណៈរដ្ឋមន្ត្រី | សមាជិក |

| | | |
|---|---|---|
| ៣ -ឯកឧត្តម **ជា ឧុធណា** | តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៤ -ឯកឧត្តម **សុន វី** | អគ្គនាយកនៃទូរគមនាគមន៍កម្ពុជា | សមាជិក |
| ៥ -តំណាងនិយោជិត | ទូរគមនាគមន៍កម្ពុជា ០១រូប | សមាជិក |

**មាត្រា ២._**

សមាសភាពក្រុមប្រឹក្សាភិបាលដូចមានចែងក្នុងមាត្រា១ ត្រូវបានតែងតាំងសម្រាប់រយៈពេល០៣(បី)ឆ្នាំ អាណត្តិនេះអាចបន្តជាថ្មីទៀតបាន ។

**មាត្រា ៣._**

មុខងាររបស់ក្រុមប្រឹក្សាភិបាល ត្រូវបានបញ្ចប់បន្ទាប់ពីការប្រជុំក្រុមប្រឹក្សាភិបាល ដែលបានពិភាក្សាសម្រេចលើគណនីនៃការិយបរិច្ឆេទទី៣ របស់ទូរគមនាគមន៍កម្ពុជា ។ សមាជិកក្រុមប្រឹក្សាភិបាលអាចត្រូវផ្លាស់ប្តូរដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសាមី ។

**មាត្រា ៤._**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីជនដូចមានចែងក្នុងមាត្រា១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល</u> ៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៧៧៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយសុវត្ថារា
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១ ៖** បំពាក់មេដាយ**សុវត្ថារា ថ្នាក់ធិបឌិន្ទ** ជូនមន្ត្រីនគរបាលជាតិ ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ច និងរួមចំណែកអភិវឌ្ឍស្រុកកញ្ជៀច និងស្រុកស្វាយអន្ទរ ខេត្តព្រៃវែង ឱ្យមានការរីកចម្រើន មានដូចខាងក្រោម:

| | | | |
|---|---|---|---|
| ១- | វរសេនីយ៍ទោ | គី គឹមលី | នាយការិយាល័យ |
| ២- | វរសេនីយ៍ទោ | សុខ ខា | នាយរងការិយាល័យ |
| ៣- | វរសេនីយ៍ទោ | ដួង សំអាង | នាយរងការិយាល័យ |
| ៤- | វរសេនីយ៍ទោ | គឹម កណ្ណារិទ្ធ | នាយរងការិយាល័យ |
| ៥- | វរសេនីយ៍ទោ | មុំ សុគន្ធរដ្ឋា | នាយរងការិយាល័យ |
| ៦- | វរសេនីយ៍ទោ | សេង នី | នាយរងការិយាល័យ |
| ៧- | វរសេនីយ៍ទោ | អ៊ុំ មាលា | នាយរងការិយាល័យ |
| ៨- | វរសេនីយ៍ទោ | កុយ ហេង | នាយរងការិយាល័យ |
| ៩- | វរសេនីយ៍ទោ | ប៉ែន វណ្ណា | នាយរងការិយាល័យ |
| ១០- | វរសេនីយ៍ទោ | នាក់ សំអុល | នាយរងការិយាល័យ |
| ១១- | វរសេនីយ៍ទោ | ពៅ សុធារៈ | នាយរងការិយាល័យ |
| ១២- | វរសេនីយ៍ទោ | ឆាយ ប៊ុនថន | នាយរងការិយាល័យ |
| ១៣- | លោកស្រីវរសេនីយ៍ត្រី | អ៊ឹង ច័ន្ទវឌ្ឍនា | នាយផ្នែក |

១៤- លោកស្រីអនុសេនីយ៍ឯក ប៊ួយ បាឡាត់ នាយរងផ្នែក

**មាត្រា២៖** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលនៃគណៈអភិបាលខេត្តព្រៃវែង និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៥៥៣ អនក្រ.បក

**អនុក្រឹត្យ**
**ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ**
**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សម្រេច**

**មាត្រា១ ៖** បំពាក់**មេដាយមុនីសារាភ័ណ្ឌ** ជូនមន្ត្រីនគរបាលជាតិ ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ច និងរួមចំណែកអភិវឌ្ឍស្រុកកញ្ជៀច និងស្រុកស្វាយអន្ទរ ខេត្តព្រៃវែង ឱ្យមានការរីកចម្រើន មានដូចខាងក្រោម:

**ក-គ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ ថ្នាក់ធិបឌិន្ទ ចំនួន ០៨គ្រឿង:**

| | | | |
|---|---|---|---|
| ១- | វរសេនីយ៍ទោ | ឃ្លោក សុផល | នាយរងការិយាល័យ |
| ២- | វរសេនីយ៍ទោ | អ៊ុក ច័ន្ទតារា | នាយរងការិយាល័យ |
| ៣- | វរសេនីយ៍ទោ | វ៉េង ហុង | នាយរងការិយាល័យ |
| ៤- | វរសេនីយ៍ត្រី | ធូ សារ៉ែន | នាយរងការិយាល័យ |
| ៥- | វរសេនីយ៍ត្រី | ឡេង វាសនា | នាយរងការិយាល័យ |
| ៦- | វរសេនីយ៍ទោ | សៃ វុត្ថា | នាយរងការិយាល័យ |
| ៧- | អនុសេនីយ៍ឯក | អ៊ឹង រដ្ឋា | នាយរងផ្នែក |
| ៨- | អនុសេនីយ៍ទោ | រស់ សុវណ្ណារ៉ា | នាយរងផ្នែក |

**ខ-គ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ ថ្នាក់សេនា ចំនួន ១៥គ្រឿង:**

| | | | |
|---|---|---|---|
| ១- | លោកស្រីវរសេនីយ៍ទោ | គឹម លន | នាយរងការិយាល័យ |
| ២- | វរសេនីយ៍ត្រី | កៅ បឿន | នាយរងការិយាល័យ |

| | | | |
|---|---|---|---|
| ៣- | វរសេនីយ៍ត្រី | សំ ចុល | នាយរងការិយាល័យ |
| ៤- | វរសេនីយ៍ត្រី | នុត សំអាត | នាយរងការិយាល័យ |
| ៥- | អនុសេនីយ៍ឯក | នុត សុខ | នាយរងការិយាល័យ |
| ៦- | លោកស្រីវរសេនីយ៍ត្រី | ងួន សុផុន | នាយផ្នែក |
| ៧- | អនុសេនីយ៍ឯក | អ៊ួន យ៉ុង | នាយផ្នែក |
| ៨- | អនុសេនីយ៍ឯក | អ៊ាង គឹមងួន | នាយផ្នែក |
| ៩- | អនុសេនីយ៍ឯក | ហេង សុផានិត | នាយរងផ្នែក |
| ១០- | អនុសេនីយ៍ឯក | ញ៉ឹប ពិសិដ្ឋ | នាយរងផ្នែក |
| ១១- | លោកស្រីអនុសេនីយ៍ឯក | ហាម វណ្ណធី | នាយរងផ្នែក |
| ១២- | អនុសេនីយ៍ឯក | សាយ សុជាតិ | នាយរងផ្នែក |
| ១៣- | អនុសេនីយ៍ទោ | ចាន់ វណ្ណឌី | នាយរងផ្នែក |
| ១៤- | អនុសេនីយ៍ទោ | អ៊ី សុធារិទ្ធ | នាយរងផ្នែក |
| ១៥- | ព្រិន្ទបាលឯក | ធុច ម៉ុងស្រី | មន្ត្រី |

**គ-គ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ ថ្នាក់អស្សឫទ្ធិ ចំនួន ២២គ្រឿង:**

| | | | |
|---|---|---|---|
| ១- | វរសេនីយ៍ឯក | ថ្លាង ភិនរ៉ា | នាយការិយាល័យ |
| ២- | វរសេនីយ៍ទោ | ជា ចុល | នាយរងការិយាល័យ |
| ៣- | វរសេនីយ៍ត្រី | ឃឹម សំអាត | នាយរងការិយាល័យ |
| ៤- | វរសេនីយ៍ត្រី | ធីវ ខេមរិទ្ធ | នាយរងការិយាល័យ |
| ៥- | វរសេនីយ៍ត្រី | ស៊ិន សុផល | នាយរងការិយាល័យ |
| ៦- | វរសេនីយ៍ត្រី | សុន សំបូរ | នាយរងការិយាល័យ |
| ៧- | វរសេនីយ៍ត្រី | ថោង សាលាប | នាយរងការិយាល័យ |
| ៨- | អនុសេនីយ៍ទោ | ហេង សុផល | នាយរងការិយាល័យ |
| ៩- | វរសេនីយ៍ត្រី | អ៊ុយ សុខវឌ្ឍី | នាយផ្នែក |
| ១០- | វរសេនីយ៍ត្រី | មាជ ភារុណ | នាយផ្នែក |
| ១១- | វរសេនីយ៍ត្រី | ស៊ិន សុខចំរើន | នាយផ្នែក |
| ១២- | វរសេនីយ៍ត្រី | គឹម ឡុង | នាយផ្នែក |
| ១៣- | អនុសេនីយ៍ឯក | ហឹង លី | នាយផ្នែក |
| ១៤- | អនុសេនីយ៍ឯក | ជឹម ចាន់ធឿន | នាយរងផ្នែក |
| ១៥- | អនុសេនីយ៍ឯក | ជួ សារ៉ាត់ | នាយរងផ្នែក |
| ១៦- | អនុសេនីយ៍ឯក | សន សារិទ្ធ | នាយរងផ្នែក |
| ១៧- | អនុសេនីយ៍ឯក | សេក សំអាន | នាយរងផ្នែក |
| ១៨- | លោកស្រីអនុសេនីយ៍ទោ | សរ សារ៉ាន់ | នាយរងផ្នែក |
| ១៩- | អនុសេនីយ៍ទោ | ជួន រស្មី | នាយរងផ្នែក |
| ២០- | អនុសេនីយ៍ទោ | អ៊ុង ចូ | នាយរងផ្នែក |

២១- អនុសេនីយ៍ឯក សេង ជីវ័ន្ត មន្ត្រី

២២- អនុសេនីយ៍ទោ ទេព សំអុល មន្ត្រី

**មាត្រា២៖** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលនៃគណៈអភិបាលខេត្តព្រៃវែង និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៧៧៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងផ្លាស់ប្តូរមុខងារ នាយទាហាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលតួនាទី ភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំង របស់អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា១ៈ** តែងតាំងផ្លាស់ប្តូរមុខងារ នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោមៈ

១-ឧត្តមសេនីយ៍ទោ **ខឹម ឧុទ្ធី** អត្តលេខ ០០៨៩៨១ ជា អគ្គលេខាធិការរង នៃអាជ្ញាធរជាតិទប់ស្កាត់អាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម

២-ឧត្តមសេនីយ៍ទោ **ចាន់ ដារ៉ារិទ្ធ** អត្តលេខ ០៣៨៨៨១ ជា ប្រធាន ជំនាញគ្រប់គ្រងធនធានមនុស្ស និងបណ្តុះបណ្តាល មជ្ឈមណ្ឌលជាតិគ្រប់គ្រងកងកម្លាំង រក្សាសន្តិភាព បោសសំអាតមីន និងកាកសំណល់សង្គ្រាម

**មាត្រា២ៈ** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធនិងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួលៈ**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២២៥ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមន្ត្រីរាជការ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៥ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច
- បានឃើញអនុក្រឹត្យលេខ ០៣ អនក្រ.បក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច

### សម្រេច

**មាត្រា១ .-** ត្រូវបានតែងតាំងលោក **សុជាត យុត្តិធន** អត្តលេខ ១៨២១២០០២១៧ ក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ឋានន្តរសក្តិវរមន្ត្រី ថ្នាក់លេខ៤ ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

**មាត្រា២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ២២៦ អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ**

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សម្រេច**

**មាត្រា១ ៖** បំពាក់មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ធិបឌិន្ទ ជូនមន្ត្រីនគរបាលជាតិ ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ច និងរួមចំណែកអភិវឌ្ឍខេត្តព្រះសីហនុ ឱ្យមានការរីកចម្រើន មានដូចខាងក្រោម:

១- អនុសេនីយ៍ឯក យាង សុជាតិ អត្តលេខ ៦៣៨៤២

២- អនុសេនីយ៍ទោ ហ៊ីង ពុទ្ធិកា អត្តលេខ ៦៣៨៦១

៣- អនុសេនីយ៍ត្រី ងី ណាត្រី អត្តលេខ ៦៣៨៥៥

**មាត្រា២ ៖** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ២២៧ អនក្រ.តត

**អនុក្រឹត្យ**

**ស្តីពីការជូនមេដាយការងារ**

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សម្រេច**

**មាត្រា១ ៖** បំពាក់មេដាយការងារ ជូនអស់លោក លោកស្រី មន្ត្រីរាជការ ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ច និងរួមចំណែកអភិវឌ្ឍខេត្តព្រះសីហនុ ឱ្យមានការរីកចម្រើន មានដូចខាងក្រោមៈ

**ក-មេដាយការងារ ថ្នាក់មាស ចំនួន ០៩គ្រឿងៈ**

| | | | |
|---|---|---|---|
| ១- | លោក | នៅ ធុន | ប្រធានការិយាល័យ នៃមន្ទីរបរិស្ថានខេត្ត |
| ២- | លោក | ទេព ស៊ីណូរ៉ា | អនុប្រធានការិយាល័យ នៃមន្ទីរបរិស្ថានខេត្ត |
| ៣- | លោកស្រី | ទេព សុវណ្ណៈ | អនុប្រធានការិយាល័យ នៃមន្ទីរបរិស្ថានខេត្ត |
| ៤- | លោក | សោម ច័ន្ទណារិទ្ធិ | ប្រធានការិយាល័យ នៃមន្ទីរបរិស្ថានខេត្ត |
| ៥- | លោក | មូ ឆាយ | ប្រធានការិយាល័យ នៃមន្ទីរបរិស្ថានខេត្ត |
| ៦- | លោក | ហ៊ិន វ៉េត | អនុប្រធានការិយាល័យ នៃមន្ទីរបរិស្ថានខេត្ត |
| ៧- | លោក | អួន អេម | ប្រធានការិយាល័យភ្នាក់ងារបរិស្ថានស្រុកព្រៃនប់ |
| ៨- | លោក | លី នាង | មន្ត្រីនៃមន្ទីរបរិស្ថានខេត្តព្រះសីហនុ |
| ៩- | លោក | ឃួន ប៊ុនសៃ | មន្ត្រីនៃមន្ទីរបរិស្ថានខេត្តព្រះសីហនុ |

**ខ-មេដាយការងារ ថ្នាក់សំរិទ្ធ ចំនួន ២២គ្រឿងៈ**

| | | | |
|---|---|---|---|
| ១- | លោក | ឡុង សូរីនណា | មន្ត្រីនៃមន្ទីរបរិស្ថានខេត្តព្រះសីហនុ |
| ២- | លោកស្រី | អាន វង្សវត្តី | មន្ត្រីនៃមន្ទីរបរិស្ថានខេត្តព្រះសីហនុ |
| ៣- | លោក | ទូច នន | មន្ត្រីនៃមន្ទីរបរិស្ថានខេត្តព្រះសីហនុ |

| | | | |
|---|---|---|---|
| ៤- | លោក | មាស សុទ្ធា | មន្ត្រីនៃមន្ទីរបរិស្ថានខេត្តព្រះសីហនុ |
| ៥- | លោក | ញឹម សុវណ្ណារិទ្ធ | មន្ត្រីនៃមន្ទីរបរិស្ថានខេត្តព្រះសីហនុ |
| ៦- | លោក | ម៉ើង វ៉ាន់ថា | មន្ត្រីនៃមន្ទីរបរិស្ថានខេត្តព្រះសីហនុ |
| ៧- | លោក | ម៉ូវ ឡាំ | ឧទ្យានុរក្សឧទ្យានជាតិព្រះសុរាម្រិត កុសមៈ "គីរីរម្យ" |
| ៨- | លោក | ទឹម ប្រុស | ឧទ្យានុរក្សឧទ្យានជាតិព្រះសុរាម្រិត កុសមៈ "គីរីរម្យ" |
| ៩- | លោក | ចែម ម៉ឺន | ឧទ្យានុរក្សឧទ្យានជាតិព្រះសុរាម្រិត កុសមៈ "គីរីរម្យ" |
| ១០- | លោក | ទឹម សីយ | ឧទ្យានុរក្សឧទ្យានជាតិព្រះសុរាម្រិត កុសមៈ "គីរីរម្យ" |
| ១១- | លោក | ឆយ យ៉ាន់ | ឧទ្យានុរក្សឧទ្យានជាតិព្រះមុនីវង្ស "បូកគោ" |
| ១២- | លោក | កង វិសុទ្ធ | ឧទ្យានុរក្សឧទ្យានជាតិព្រះមុនីវង្ស "បូកគោ" |
| ១៣- | លោក | ស្វាយ ហុន | ឧទ្យានុរក្សឧទ្យានជាតិព្រះមុនីវង្ស "បូកគោ" |
| ១៤- | លោក | កែវ ដា | ឧទ្យានុរក្សឧទ្យានជាតិព្រះមុនីវង្ស "បូកគោ" |
| ១៥- | លោក | ឃាន វាសនា | ឧទ្យានុរក្សឧទ្យានជាតិព្រះមុនីវង្ស "បូកគោ" |
| ១៦- | លោក | ថោង ដួយ | ឧទ្យានុរក្សឧទ្យានជាតិព្រះមុនីវង្ស "បូកគោ" |
| ១៧- | លោក | ប៊ុន ណារ៉ាត់ | ឧទ្យានុរក្សឧទ្យានជាតិព្រះមុនីវង្ស "បូកគោ" |
| ១៨- | លោក | ហែម ពោ | មន្ត្រីឧទ្យានជាតិព្រះសីហនុ "រាម" |
| ១៩- | លោក | សុខ ហម | មន្ត្រីឧទ្យានជាតិព្រះសីហនុ "រាម" |
| ២០- | លោក | សាយ កៅ | មន្ត្រីឧទ្យានជាតិព្រះសីហនុ "រាម" |
| ២១- | លោក | ម៉ាន ឧត | មន្ត្រីឧទ្យានជាតិព្រះសីហនុ "រាម" |
| ២២- | លោក | សួន សុង | មន្ត្រីឧទ្យានជាតិព្រះសីហនុ "រាម" |

**មាត្រា២៖** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ កុម្ភៈ ឆ្នាំ ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៤៤៨ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការផ្លាស់ប្តូរប្រភេទក្របខ័ណ្ឌមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០០/០៥៦ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីក្រមការ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១ .-** ប្តូរប្រភេទក្របខ័ណ្ឌជាករណីពិសេស ដល់លោក **ហុក សិទ្ធី** ពីឋានន្តរស័ក្តិលេខាធិការដ្ឋបាល ថ្នាក់លេខ ៩ នៃក្របខ័ណ្ឌលេខាធិការដ្ឋបាល មកឋានន្តរស័ក្តិក្រមការ ថ្នាក់លេខ ៤ នៃក្របខ័ណ្ឌមន្ត្រីក្រមការ នៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅ រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល***
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា "២"*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៧៧៩ អនក្រ.តត

## អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមន្ត្រីរាជការ
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រង នៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១** .- តែងតាំងលោក **អ៊ូ សុផល** ជាប្រធាននាយកដ្ឋានហិរញ្ញវត្ថុ នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងសាធារណការ និងដឹកជញ្ជូន ជំនួសលោក **អ៊ុក ច័ន្ទតារា** ដែលបានចូលនិវត្តន៍។

**មាត្រា ២** .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ២០១៧*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល៖*
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៣០ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការសម្រួលភារកិច្ចមន្ត្រីនគរបាលជាតិ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សម្រេច

**មាត្រា ១** : ត្រូវបានសម្រួលភារកិច្ចមុខតំណែងនាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ចំនួន ០២រូប នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ ដូចមានរាយនាមខាងក្រោម ៖

១-លោកឧត្តមសេនីយ៍ទោ **កែម សារិន** អត្តលេខ ៥៧៨៨១ ពីប្រធាននាយកដ្ឋានរដ្ឋបាល-សរុប ទៅជាប្រធាននាយកដ្ឋានជនបរទេសអន្តោប្រវេសន្តជាអ្នកវិនិយោគឯកជន។

២-លោកឧត្តមសេនីយ៍ទោ **ពុំ វិចិត្រា** អត្តលេខ ០៦៣៨ ពីប្រធាននាយកដ្ឋានជនបរទេសអន្តោប្រវេសន្តជាអ្នកវិនិយោគឯកជន ទៅជាប្រធាននាយកដ្ឋានរដ្ឋបាល-សរុប។

**មាត្រា ២** : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមុីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី [illegible] ខែ កុម្ភៈ ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល:</u>
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៧៣១ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ ឯកឧត្តម អូស្មាន ហាស្សាន់ រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី

**សម្រេច**

**មាត្រា ១.**-បំពាក់ **មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា** ចំនួន ០២គ្រឿង ជូនសប្បុរសជន ចំនួន ០២រូប ដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួន ចូលរួមជួយកសាងអគារមជ្ឈមណ្ឌលអភិវឌ្ឍន៍សហគមន៍ និងអគារអន្តេវាសិកដ្ឋាន ស្ថិតនៅភូមិ៤ សង្កាត់ច្រាំងចំរេះ១ និងភូមិ១ ច្រាំងចំរេះ២ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កន្លងមក ដូចមានរាយនាមខាងក្រោម៖

| | | | |
|---|---|---|---|
| ១- | លោក | **ម៉ាត់ អត្ថណាន** | សប្បុរសជន |
| ២- | លោក | **សុះ សៅអ៊ី** | សប្បុរសជន |

**មាត្រា ២.**-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី២៦ ខែ កុម្ភៈ ឆ្នាំ ២០១៧*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ ៧៣៧ អនក្រ.តត

**អនុក្រឹត្យ**
**ស្តីពីការជូនមេដាយស្ថាបនាជាតិ**
**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ ឯកឧត្តម អូស្មាន ហាស្សាន់ រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី

**សម្រេច**

**មាត្រា ១.**_បំពាក់ **មេដាយសិរីវឌ្ឍស្ថាបនាជាតិ** ចំនួន ០២គ្រឿង ជូនសប្បុរសជន ចំនួន ០២រូប ដែលបានបរិច្ចាគ ថវិកាផ្ទាល់ខ្លួនចូលរួមជួយកសាងអគារមជ្ឈមណ្ឌលអភិវឌ្ឍន៍សហគមន៍ និងអគារអន្តេវាសិកដ្ឋាន ស្ថិតនៅភូមិ៤ សង្កាត់ច្រាំងចំរេះ១ និងភូមិខ១ ច្រាំងចំរេះ២ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កន្លងមក ដូចមានរាយនាមខាងក្រោម៖

| | | | |
|---|---|---|---|
| ១- | លោក | **សេន អ៊ី** | សប្បុរសជននៅប្រទេសកម្ពុជា |
| ២- | លោក | **លី ឡាហៃ** | សប្បុរសជននៅប្រទេសកម្ពុជា |

**មាត្រា ២.**_រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ខែ កុម្ភៈ ឆ្នាំ ២០១៧*
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៤៣៣ អនក្រ.តត

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

## សម្រេច

**មាត្រា១.-** បំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីជំនាញ ចំនួន១១រូប ដែលមានស្នាដៃល្អក្នុងការសិក្សាស្រាវជ្រាវ និងអភិរក្សជួសជុលប្រាសាទសំបូរព្រៃគុក ដូចមានរាយនាមខាងក្រោម ៖

**ក-មេដាយមាសស្ថាបនាជាតិ**

១-លោកស្រីបណ្ឌិត សូ សុគន្ធារី ស្ថាបត្យករ សាស្ត្រាចារ្យសាកលវិទ្យាល័យន័រគុន នាយិកាប្រតិបត្តិគម្រោងអភិរក្ស SPK

២-លោក ពី សុផាត អ្នកជំនាញជួសជុលប្រាសាទ (កំរិតខ្ពស់)

៣-លោក យ៉ែម យឹន អ្នកជំនាញជួសជុលប្រាសាទ (កំរិតខ្ពស់)

៤-លោក ឆាច ចក់ អ្នកជំនាញជួសជុលប្រាសាទ (កំរិតខ្ពស់)

៥-លោក គាន់ កុន អ្នកជំនាញជួសជុលប្រាសាទ (កំរិតខ្ពស់)

៦-លោក មាស ពូក អ្នកជំនាញជួសជុលប្រាសាទ (កំរិតខ្ពស់)

៧-លោក ក្រូច សុរិយា អ្នកជំនាញជួសជុលប្រាសាទ (កំរិតខ្ពស់)

**ខ-មេដាយប្រាក់ស្ថាបនាជាតិ**

១-លោក ទ៉ាន ទីន អ្នកជំនាញជួសជុលប្រាសាទ (កំរិតមធ្យម)

២-លោក អ៊ូច ជាតិ អ្នកជំនាញជួសជុលប្រាសាទ (កំរិតមធ្យម)

៣-លោក សឿ សាត អ្នកជំនាញជួសជុលប្រាសាទ (កំរិតមធ្យម)

៤-លោក ឆាច តី អ្នកជំនាញជួសជុលប្រាសាទ (កំរិតមធ្យម)

**មាត្រា២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ២៣៤ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

**សម្រេច**

**មាត្រា១.**_បំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ សេនា ជូនលោក **ហ៊ិន សោភ័ណ** អនុប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្តកំពង់ធំ ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិ កន្លងមក ។

**មាត្រា២.**_ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ៧៣៥ អនក្រ.បក

## អនុក្រឹត្យ
